# មជ្ឈមណ្ឌលឯកសារកម្ពុជា

សម្ភាសន៍ជាមួយ រចឹម ទន់ ហៅ ភី ភួន ហៅ ចៀម ភេទប្រុស អាយុ៦៣ឆ្នាំ

ជាជនជាតិចារាយ

មុខងារសម័យខ្មែរក្រហមៈ អតីតនិសារ អៀង សារី, នួន ជា និង ប៉ុល ពត

មុខងារបច្ចុប្បន្នៈ អតីតអភិបាលរងស្រុកម៉ាឡៃ (១៩៩៧-២០០៥)

ស្រុកកំណើតនៅភូមិកែប ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី

សព្វថ្ងៃរស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០២ៈ៤៧ៈ៣៦

៥២ទំព័រ

ដានីៈ អ៊ីមានឈ្មោះអីដែរ?

ចៀមៈ ខ្ញុំឈ្មោះ ភី ភួន ។

ដានីៈ ម៉េចបានអ្នកភូមិហៅ អ៊ី ចៀមៗៗ!

ចៀមៈ ហ្នឹងអង្គការគេហៅ ចៀម ។

ដានីៈ ឈ្មោះ ភី ភួន ហ្នឹង ឈ្មោះកំណើតរបស់អ៊ី?

ចៀមៈ អត់ទេ! ឈ្មោះកំណើតខ្ញុំ រចឹម ទន់ ។

ដានីៈ អ៊ីជនជាតិអីដែរ?

ចៀមៈ ខ្ញុំជនជាតិចារាយ ។

ដានីៈ អ៊ីសព្វថ្ងៃអាយុប៉ុន្មានហើយ?

ចៀមៈ អាយុ៦៣ ។

ដានីៈ អ៊ីសព្វថ្ងៃរស់នៅភូមិអីដែរ?

ចៀមៈ ភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានីៈ គ្រួសារអ៊ីឈ្មោះអីដែរ?

ចៀមៈ ស្រេង ប៊ុនលី ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ចៀមៈ ៥៦ ។

ដានីៈ គាត់ជនជាតិដូចអ៊ីដែរ?

ចៀមៈ អត់ទេ! គាត់នៅកំពង់ចាម ។

ដានីៈ កំពង់ចាមនៅឯណាទៅ?

ចៀមៈ នៅស្រុកជើងព្រៃ ។

ដានីៈ អ៊ីមានកូនចៅប៉ុន្មាននាក់ដែរ?

ចៀមៈ មានកូន៤នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ចៀមៈ ស្រី២ ប្រុស២ ។

ដានីៈ ពួកគាតធំៗអស់ហើយមើលទៅ?

ចៀមៈ រៀបការអស់ហើយ មានចៅ៨នាក់ ។

ដានីៈ សព្វថ្ងៃប្រកបរបររកស៊ីធ្វើអីដែរ?

ចៀមៈ ធ្វើស្រែធ្វើចំការ ។

ដានីៈ កាលមុនអ៊ីធ្វើការនៅសាលាស្រុកនេះដែរ?

ចៀមៈ បាទ! ធ្វើអភិបាលរង ។

ដានីៈ ធ្វើពីឆ្នាំណា ដល់ឆ្នាំណា?

ចៀមៈ អភិបាលរងពីឆ្នាំ ១៩៩៧ ដល់ ២០០៥ រីត្រែតតែម្តង ។

ដានីៈ អ៊ីនៅធ្វើការងារខាងបក្សទេ?

ចៀមៈ ការងារបក្សនៅធ្វើ ។

ដានីៈ បក្សប្រជាជន?

ចៀមៈ បាទ! គណៈអចិន្ត្រៃបក្សស្រុក ។

ដានីៈ អ៊ឺ ឪពុកម្តាយអ៊ីគាត់ឈ្មោះអីដែរ?

ចៀមៈ ប៉ាខ្ញុំ ឈ្មោះ ប៉ាទូត អ៊ិក ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ចៀមៈ ៩២ ។

ដានីៈ ស្រុកកំណើតអ៊ី នៅភូមិអីដែរ?

ចៀមៈ ស្រុកកំណើតឪពុកខ្ញុំ នៅភូមិថៃ ឃុំញ៉ាង ស្រុកអណ្តូងមាស ។

ដានី៖ ហ្នឹងស្រុកកំណើតអីដែរ?

ចៀម៖ ស្រុកកំណើតខ្ញុំផ្សេង ខ្ញុំនៅខាងម្ដាយខ្ញុំ នៅភូមិកែប ឃុំញ៉ាង ស្រុកអណ្ដូងមាស ។

ដានី៖ អ៊ីមានបងប្អូនបង្កើតប៉ុន្មាននាក់?

ចៀម៖ ខ្ញុំមានបងប្អូន៥នាក់ (ស្រី២ ប្រុស៣) ប្អូនស្រីស្លាប់១ហើយ សព្វថ្ងៃសល់តែ៤នាក់ទេ ។

ដានី៖ ពួកគាត់នៅរតនៈគិរី ឬមកនៅទីនេះ?

ចៀម៖ នៅរតនៈគិរីទាំងអស់ ប្អូនស្រីមួយ ធ្លាប់មកលេងស្រាប់តែទៅវិញឈឺស្លាប់ទៅ ។

ដានី៖ អ៊ីកាលពីក្មេងៗអ៊ីបានរៀនសូត្រដល់ណាដែរ?

ចៀម៖ ខ្ញុំអត់បានរៀនទេ ។

ដានី៖ ចេញពីផ្ទះពេលណាទៅ ពីឆ្នាំណាទៅ?

ចៀម៖ ខ្ញុំចេញពីផ្ទះតាំងពីឆ្នាំ១៩៦៦ ។

ដានី៖ អ៊ីចេញទៅណាខ្លះទៅកាលហ្នុង?

ចៀម៖ ចេញទៅនៅក្នុងព្រៃ ។

ដានី៖ កាលហ្នុងមានមន្ទីរ១០០ មានអីកាលហ្នុង?

ចៀម៖ ហ្នុងហើយ មាន ។

ដានី៖ កាលហ្នុងម៉េចខ្លះទៅអ៊ី?

ចៀម៖ បើនិយាយពីណាលខ្ញុំ វាវែងឆ្ងាយណាស់ កាល១៩៦៦ ហ្នុងខ្ញុំចេញទៅនៅក្នុងព្រៃ ដល់ឆ្នាំ ១៩៦៧ បានជួបឯកឧត្ដម អៀង សារី កាលហ្នុងគាត់នៅមន្ទីរ ១០២ តាប៉ុល ពត នៅមន្ទីរ ១០០ បំបែកគ្នា ។

ដានី៖ នៅក្នុងស្រុកណាទៅ?

ចៀម៖ ហ្នុងគេហៅថា នៅក្នុងភូមិកន្ទែង បើតាមមើលនៅក្នុងស្រុកបរកែវ មន្ទីរ ១០០ និង ១០២ នោះ ។

ដានី៖ ចុះអ៊ីៗផ្សេងៗទៀតទេ?

ចៀម៖ ឃើញមុនដំបូងនោះមានតែ អ៊ី អៀង សារី មុនគេ ហើយតាប៉ុល ពត ហើយមានដែរ តា នួន ជា គាត់ទៅដល់ហ្នុងដែរ ហើយបានតា កុយ ធួន ។

ដានី៖ កាលហ្នុងម៉េចបានអ៊ីបានទៅនៅជាមួយពួកគាតហ្នុង?

ចៀម៖ នៅក្នុងភូមិខ្ញុំមានបងថ្លៃខ្ញុំ គាត់អ្នកតស៊ូ ឈ្មោះបងឡាវ១ ស្លាប់បាត់ហើយ គាត់ចលនាឲ្យ ចូលបដិវត្តន៍ណា ។

ដានី៖ កាលហ្នឹងចូលបដិវត្តន៍មានគ្នាប៉ុន្មាននាក់?

ចៀម៖ ភូមិខ្ញុំ នៅតែ២នាក់ទេ បងស្រីខ្ញុំមួយ និងខ្ញុំ ប៉ុន្តែគាត់នៅបានកន្លះឆ្នាំ គាត់ជាស្រីដែរ គាត់ឈឺ គាត់ពិបាក គាត់ទៅ ផ្ទះវិញទៅ ។

ដានី៖ បងស្រីអីបង្កើត?

ចៀម៖ បងស្រីជីដូនមួយ ។

ដានី៖ គាត់ឈ្មោះអីទៅ?

ចៀម៖ គាត់ស្លាប់បាត់ហើយ គាត់ឈ្មោះ ចំប៉ៀល កាលហ្នឹងមានគ្នាច្រើនមកពីភូមិនេះ ភូមិនោះណា! ហើយភូមិខ្ញុំមានតែ២នាក់បងប្អូនទេណា ដល់នៅព្រៃមួយរយៈទៅជួប អ៊ឹមអៀង សារី ជួបអ៊ឹ ប៉ុល ពត ហ្នឹងទៅ ដល់ក្រោយមកទៀតក៏មានចលនាធ្វើស្រែ ១៩៦៨, ៦៩ ។

ដានី៖ ធ្វើនៅម្តុំមន្ទីរ ១០២, មន្ទីរ ១០០ ហ្នឹងដែរ?

ចៀម៖ មិនមែនទេ ធ្វើស្រែនៅភូមិពូនលែ នៅក្នុងឃុំបរខាំ ស្រុកបរកែវ ។

ដានី៖ កាលហ្នឹងមានគ្នាច្រើនទេធ្វើស្រែហ្នឹង?

ចៀម៖ កាលហ្នឹងមានគ្នា១៩នាក់ទេ ប៉ុន្តែដល់ពេលស្ទូង ដល់ពេលច្រូតគឺមានកងចល័ត បង្កើតកងចល័តដល់ពេលខែយើងស្ទូង គេមកជួយស្ទូង អ្នកភូមិជុំវិញហ្នឹងក៏មកជួយស្ទូងដែរណា ដល់ពេលប្រមូលផល ច្រូតហ្នឹងក៏គេមកជួយច្រូតដែរ ។

ដានី៖ ផលហ្នឹងយើងសម្រាប់ផ្គត់ផ្គង់តែក្នុងមន្ទីរ ឬយ៉ាងម៉េច?

ចៀម៖ បាទ! សម្រាប់ផ្គត់ផ្គង់ក្នុងមន្ទីរ និងផ្គត់ផ្គង់កងទ័ព ។

ដានី៖ កាលហ្នឹងយើងមានកងទ័ពហើយ?

ចៀម៖ មានហើយ! កងចល័តមិញហ្នឹង កងទ័ព ។

ដានី៖ កាលហ្នឹងមានច្រើន ឬមានតិច?

ចៀម៖ ម៉ាភូមិភាគឥសាន មិនច្រើនប៉ុន្មានទេ ប្រហែល៣០០នាក់ជាងទេ ។

ដានី៖ កាលនោះ នៃ សារ៉ាន ហៅ យ៉ា គាត់នៅហ្នឹងដែរ ឬយ៉ាងម៉េច?

ចៀម៖ បាទ! នៅហ្នឹងដែរ ដំបូងគាត់នៅមណ្ឌលគិរីទេ ដល់ក្រោយមក គាត់មកធ្វើការជួបគ្នាម្តងៗណា មកធ្វើការជាមួយតាប៉ុល ពត ជាមួយអ៊ឹមអៀង សារី ។

ដានី៖ អ៊ឹមអៀង សារី តាប៉ុល ពត គាត់ទៅនៅហ្នឹង ឆ្នាំ១៩៦៦ ឬតាំងពីមុនហ្នឹងទៀត?

ចៀម៖ ខ្ញុំជួបគាត់ ជួប១៩៦៧ មុនហ្នឹងមិនដឹងថាគាត់នៅឯណា ខ្ញុំអត់ដឹងទេណា ខ្ញុំដឹងតែពីហ្នឹងមក ។

ដានី៖ កាលហ្នឹងនៅធ្វើស្រែនៅហ្នឹងទៅ?

ចៀម៖ ធ្វើស្រែនៅហើយ ដល់ឆ្នាំ៧០រដ្ឋប្រហារណា តាប៉ុល ពត គាត់ត្រឡប់មកពីប៉េកាំងតាមវៀតណាម ។

ដានី៖ ចុះសម្ដេចកាលហ្នឹង?

ចៀម៖ សម្ដេចនៅទេ មិនទាន់មកទេ តាប៉ុល ពត ឆ្នាំ១៩៦៩ គាត់ឡើងទៅហាណូយ ឡើងទៅបេកាំង កាលរដ្ឋប្រហារ គាត់នៅក្រៅទេ ដល់រដ្ឋប្រហាហើយ ខែ៥ឆ្នាំ១៩៧០ គាត់ចុះមកវិញ គាត់ មកដល់កន្ទុយនាគនេះ ដល់ហើយបានធ្វើដំណើរពីកន្ទុយនាគ មកដល់កំពង់ចាមនេះ ខ្ញុំមកជាមួយគាត់ ឯអឹអៀង សារី ពេលចុះមកនេះ គាត់ឡើងទៅហាណូយ ឡើងទៅបេកាំងទៅរមសម្ដេច សីហនុ បានបង្កើតជារណសិរ្សរួបរួមជាតិកម្ពុជា ។ ឯពួកខ្ញុំដើរពីខែ៥ រហូតដល់ ខែ១២បានមកដល់កំពង់ចាម ដើរ៧ខែ ។

ដានី៖ ដើរគ្នាច្រើនទេកាលហ្នឹង?

ចៀម៖ ដើរគ្នា៨០នាក់ជាង ។

ដានី៖ មានតាប៉ុល ពត....

ចៀម៖ មានតែគាត់ទេដែលអ្នកដឹកនាំ គាត់ គ្រួសារគាត់ ។

ដានី៖ ខៀវ ប៉ុណ្ណារី?

ចៀម៖ បាទ!

ដានី៖ កាលហ្នឹងអឹមកចូលរួមជាមួយគាត់ ដើរគ្នា៨០នាក់ហ្នឹង មានបងប្អូនជនជាតិ ឬក៏....

ចៀម៖ បាទ! ភាគច្រើនបងប្អូនជនជាតិទាំងអស់ ខ្មែរមាន ទាវ អុល ថ្នាក់កម្មាភិបាលបញ្ញាជនមកជាមួយគ្នា ។

ដានី៖ អឹមានតួនាទីអីដែរកាលហ្នឹង?

ចៀម៖ ខ្ញុំគ្មានតួនាទីអីទេ ខ្ញុំនៅផ្នែកការពារ ។

ដានី៖ កងការពារ តាប៉ុល ពត?

ចៀម៖ បាទ! កងការពារ បើកផ្លូវ បើកអីណា ខ្ញុំកាន់អាវេប៉ាដេ បើមានបញ្ហាខ្ញុំអីខ្ញុំអ្នកដោះស្រាយបញ្ហា ប៉ុនមិនអីទេ ដើរតាមផ្លូវសុខសប្បាយរហូត អត់មានស្អីដែរ ។

ដានី៖ គាត់មាននិរសារផ្សេងទៀតដែរ?

ចៀម៖ មានច្រើន!

ដានី៖ និរសារគាត់បងប្អូនជនជាតិយើងដែរ?

ចៀមៈ បាទ! ប៉ុនខ្លះក៏ស្លាប់ និរសារគាត់ផ្ទាល់ស្លាប់អស់៣,៤, ៥នាក់ដែរ ស្លាប់អស់ហើយ អ្នកខ្លះចេញពីគាត់ កាលឆ្នាំ១៩៧២ ចេញទៅធ្វើមេទ័ពណា ខ្លះស្លាប់នៅព្រៃគ្រី សណ្ដែក ទន្លេសាប (ព្រំប្រទល់កំពង់ឆ្នាំង-ដើមព្រៃ, បាធាយ កំពង់ចាម) ដិះពីព្រៃគ្រី បានដិះ គាណូតមកបានឆ្លងមកគាជេស នៅក្នុងកំឡុងសង្គ្រាម៥ឆ្នាំ ។

ដានីៈ អីចឹងដើរ៥ខែ ពីហ្នឹងមក?

ចៀមៈ ដើរ៧ខែ មកពីខែ៥ ដល់ខែ១២ បានដល់ ។

ដានីៈ មកដល់ព្រៃគ្រីហ្នឹង?

ចៀមៈ អត់ទេ! មកដល់ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម សង្គ្រាម៥ឆ្នាំ មូលដ្ឋានធំនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

ដានីៈ អូ! ខ្ញុំមានស្រុកកំណើតនៅស្រុកស្ទឹងត្រង់ នៅដីដុះ ព្រែកសង្កែ!

ចៀមៈ អីចឹង! ខ្ញុំ ដើរតាមនោះដែរតើ ដើរតាមព្រែកសង្កែ ដីដុះ ឆ្លងទៅខាង២០៣ ខាងបូព៌ា ក្រូចឆ្មារ កាលសង្គ្រាម៥ឆ្នាំ ខ្ញុំធ្វើដំណើរជាមួយអ៊ំ នួន ជា ។

ដានីៈ នួន ជា គាត់ធ្វើដំណើរតាមដីដុះព្រែកសង្កែហ្នឹងដែរ?

ចៀមៈ បាទ! គាត់ធ្វើដំណើរទៅធ្វើការជាមួយសោ ភឹម ២០៣ បូព៌ា តាសោ ភឹម ណា ។

ដានីៈ ចុះមន្ទីរនៅខាងស្ទឹងត្រង់នៅម្ដុំណាទៅ?

ចៀមៈ មន្ទីរនៅក្នុងព្រៃ នៅខាងលិច ខាងកើត ចល័តពេញតែព្រៃកាលហ្នុងណា តាមស្ទឹងជីនិត នោះផង តាមទឹកប្រោះនោះផង ដឹងឯណា ឯណីខ្លះទេ ។

ដានីៈ ចុះខាងបិតន្ទូនោះ?

ចៀមៈ ហ្នឹងហើយខាងបិតន្ទូ វាមាន ប២០ ប១៧ ប១៩ ប២៤ ប៣០ ប៣១ ច្រើនណាស់ ចល័តចុះឡើង ។

ដានីៈ ចុះអ៊ំ! ដូចថាកាលនៅរតនៈគិរី គេដាក់ថា មន្ទីរ ១០០, មន្ទីរ ១០២ ម៉េចបានគេដាក់ អីចឹង?

ចៀមៈ អាហ្នឹងគេដាក់លេខអីចឹង ឧបមាថា តាប៉ុល ពត មន្ទីរ១០០អីចឹងទៅណា ចេញពី មន្ទីរ១០០ ដឹងថា តា ប៉ុល ពតហើយ លេខសម្ងាត់របស់គាត់ មន្ទីររបស់គាត់ បើ លេខ១០២ ដឹងថាអ៊ំ អៀង សារី ហើយ ។

ដានីៈ គេចំណាំអីចឹង!

ចៀមៈ ហ្នឹងហើយ! ដូចថាយើងមើលសំបុត្រហ្នឹង គេការខ្ទង់ថា ផ្ញើរជូនមន្ទីរ១០០ យកទៅឲ្យ ១០០ទៅ ផ្ញើរជូន១០២ គេអត់ដាក់ ប៉ុល ពត អត់ដាក់ អៀង សារី អីទេកាលនោះ ដាក់តែលេខ ១០២ ឧបមាថាយើងនិរសារ យើងដឹងបញ្ជូនតាមនោះ។

ដានីៈ អ៊ីធ្លាប់ធ្វើនិរសារដែរ?

ចៀមៈ ធ្វើដែរតើស!

ដានីៈ អ៊ីធ្វើនិរសារឲ្យ....

ចៀមៈ ខ្ញុំធ្វើនិរសារនែ ចុះពីឆ្នាំ៧០មក ខ្ញុំធ្វើនិរសារឲ្យអ៊ីប៉ុល ពត ផ្ទាល់ម៉ង ជូនគាត់ទៅសមរភូមិ ជូនគាត់ទៅភូមិភាគអីចឹងទៅណា...។

ដានីៈ តាំងពីចុះមកអ៊ីចាប់ធ្វើនិរសារឲ្យគាត់?

ចៀមៈ បាទ!

ដានីៈ កាលហ្នុងយើងនិរសារយើងយ៉ាងម៉េច យើងរត់សំបុត្រ!

ចៀមៈ បាទ!

ដានីៈ យើងរត់យ៉ាងម៉េចទៅ សំបុត្រហ្នឹង?.

ចៀមៈ សំបុត្រហ្នឹងឧបមាថាឥឡូវ ចេញពីមន្ទីរ ចេញពីគាត់អីចឹង ឧបមាថាទៅសមរភូមិកាលហ្នុង សុន សេន កាន់សមរភូមិ, ៣០៤ហ្នឹង កុយ ធួន, ខាង២០៣ហ្នឹង សោ ភឹម ខាងនិរតី តាម៉ុក អីចឹងទៅណា ពាយ័ព្យ តាញឹម អីចឹង ដល់អីចឹងយើងនាំដាក់ហ្នុងទៅ។

ដានីៈ ចុះយើងមានអីជិះ ឧបមាថាកាលឆ្នាំ៧០ នៅស្ទឹងត្រង់ បើយើងទៅតាមភូមិភាគវាទៅឆ្ងាយៗ ចុះយើងជិះអីទៅ?

ចៀមៈ កាលហ្នុងដល់៧១, ៧២ យើងនៅវង្សស្រុកស្ទឹងត្រង់ ដូចជាមកកំពង់ថ្មនេះ ដូចជាមកកន្លែងយ១ កន្លែងចំការកៅស៊ូ វាមានមន្ទីរសមរភូមិអីចឹងណា យើងនាំតាអីចឹងទៅ កាលនោះគាត់ដើរបើកវគ្គកាលខែវស្សា ដើរបើកវគ្គតាមភូមិភាគ វគ្គយោធា វគ្គមួយទៀតហៅថាចម្រុះ មានតំបន់ មានស្រុកអីចឹងណា ភូមិភាគ។

ដានីៈ ប៉ុន្តែអ៊ីជានិរសាអីចឹង យើងត្រូវយកមកផ្ទាល់ដៃ ឧបមាថាយើងត្រូវយកភូមិភាគ យើងត្រូវ យកទៅផ្ទាល់ដៃដល់លេខាភូមិភាគហ្នុងម៉ង ឬក៏យ៉ាងម៉េច?

ចៀមៈ បាទ! គេមាននិរសាររបស់គេដែរ យើងយកទៅដាក់កន្លែងនិរសាររបស់គេទៅនិរសារភូមិភាគ បើថាកាលណាចាំបាច់យើងទៅជួបផ្ទាល់ក៏បានដែរ បើសំបុត្រដាក់ថានាំដល់ផ្ទាល់ យើងទៅជួបផ្ទាល់ក៏បាន បើសំបុត្រល្មមៗយកទៅឲ្យតាមដំណាក់គេហ្នុងទៅ។

ដានីៈ	បើយើងត្រូវយកទៅឲ្យផ្ទាល់ យើងត្រូវធ្វើដំណើរយ៉ាងម៉េច មធ្យោបាយក្នុងការធ្វើដំណើរ?

ចៀមៈ	កាលហ្នឹងទី១ ដើរតែម្តង ដើរវាយូដែរបានដល់ ប៉ុនចាប់ពី៧៣មកយើងមានម៉ូតូ។

ដានីៈ	ពេលដែលយើងធ្វើដំណើរ យើងធ្វើដំណើរតែម្នាក់ឯង ឬក៏មានគ្នា?

ចៀមៈ	ខ្ញុំច្រើនតែដើរម្នាក់ឯង អត់មានគ្នាទេ ម្នាក់ឯងតែម្តង។

ដានីៈ	ដូចថាអ៊ីអ្នកនៅខាងរតនៈគិរី ដល់ពេលអ៊ីមកដល់កំពង់ចាម ម៉េចបានអ៊ីដឹងភូមិសាស្ត្រច្បាស់?

ចៀមៈ	អត់ទេ! កាលយើងមកពីរតនៈគិរី យើងដើរជុំគ្នាគាត់ព្រៃរហូត យើងដើរ៧ខែហ្នឹងដល់ស្រុក ស្ទឹងត្រង់យើងបោះទីតាំងនៅហ្នឹង យើងទៅតាមមូលដ្ឋានគេ យើងដើរជាមួយគាត់មួយរយៈយើងដឹង គាត់ទៅកន្លែងណា ទៅមន្ទីរនៅកន្លែងណាៗ យើងដឹងទីតាំងភូមិសាស្ត្រហើយណា។ ដល់៧៣ មានម៉ូតូ អត់អីទេ ផ្លូវជាតិមើលតាមផែនទីខ្វះអីខ្វះ ទៅណាមកណា គេមានផ្លូវរបស់គេ ៧៣ រំដោះហើយយើងប្រើម៉ូតូពីស្គន់ ព្រែកក្តាម មកខត្តគកាលហ្នឹងបោះទីតាំងនៅខេត្តកំពង់ឆ្នាំង ម្តុំអមលាំង ចេញចូលតាមផ្លូវជាតិហ្នឹង វៃរំដោ វះឆ្នាំ៧៤ ទៅតាមផ្លូវហ្នឹង ឆ្លងទន្លេទៅ។

ដានីៈ	កាលពីឆ្នាំ ៧០, ៧១, ៧២ នៅស្ទឹងត្រង់ អ៊ីមានប្រសាសន៍ថាកាលហ្នឹងមានមន្ទី ប២០ ប១៩ បអី...មានលេខយ៉ាងម៉េចគេដែរកាលហ្នឹង?

ចៀមៈ	មានលេខ ដូចថាមន្ទីរគេ មន្ទីរដែរយើងនៅចល័តនោះណា ប១៧ ជាមន្ទីរមួយទៅ ប១៩ ជាមន្ទីរមួយទៅ ប២០ មន្ទីរមួយ ប៣០ មន្ទីរមួយទៅ ៣១ មន្ទីរមួយទៅ ២៤ មានច្រើនចល័តពេញព្រៃទៅណា។

ដានីៈ	កាលមានគ្នាច្រើន មួយបៗ?

ចៀមៈ	មិនច្រើនទេ មួយបៗ ៤,៥នាក់ៗទេ អ្នកនៅប្រចាំការ៤,៥នាក់សម្រាប់ធ្វើការងារណា។

ដានីៈ	ប ហ្នឹងមានន័យថាមន្ទីរ?

ចៀមៈ	បាទ!

ដានីៈ	កាលហ្នឹងតា ប៉ុល ពត គាត់នៅប្រចាំការនៅហ្នឹងម៉ង?

ចៀមៈ	គាត់នៅហ្នឹង។

ដានីៈ	តែអ៊ី អៀង សារី គាត់អត់ទេ?

ចៀមៈ	គាត់នៅក្រៅ គាត់ទៅតាំងពី៦៩ ដល់រំដោះភ្នំពេញបានគាត់មក។

ដានី៖ អីចឹងនៅ ប ហ្នឹងមានតែតា ប៉ុល ពតទេ?

ចៀម៖ តា ប៉ុល ពត, នួន ជា និងតា ខៀវ សំផន ។

ដានី៖ ចុះ សុន សេន?

ចៀម៖ សុន សេន គាត់នៅសមរភូមិ គាត់មិនសូវមកទីនេះជាប់ទេ សមរភូមិ ឧបមាថា ចុះពេលហ្នឹង សមរភូមិកំពង់ធំ គាត់នៅទីនោះ ដកពីសមរភូមិកំពង់ធំ មកវិញកំពង់ចាមកាលហ្នឹង ដកពីកំពង់ចាម ទៅបាក់កន្ទេងនៅភ្នំពេញ វ៉ៃយកភ្នំពេញ គាត់នៅមន្ទីររបស់គាត់ បញ្ជារដោយខ្សែក ។

ដានី៖ ចុះ វ៉ន វ៉េត?

ចៀម៖ វ៉ន វ៉េត គាត់នៅតាមភូមិភាគទេ គាត់នៅភូមិភាគពិសេស និរតី តាម៉ុត ដល់កំពតតា សែ បើតាចុង នៅកោះកុង បើតា ស៊ី គាត់នៅកំពង់ស្ពឺផង កំពង់ឆ្នាំងផង ពួកគាត់សុទ្ធអ្នកបដិវត្តន៍ហើយ ។

ដានី៖ អីចឹងដល់ឆ្នាំ៧៣ តាប៉ុល ពត គាត់ផ្លាស់មន្ទីរពីស្ទឹងត្រង់កំពង់ចាម មកកំពង់ឆ្នាំង អមលាំងកំពង់ស្ពឺ?

ចៀម៖ អត់ទេ! ហ្នឹងឆ្នាំ៧៣ ប៉ុល ពត គាត់មកបញ្ជាផ្ទាល់វ៉ៃភ្នំពេញហ្នឹង ។

ដានី៖ កាលហ្នឹងគាត់នៅម្តុំណា?

ចៀម៖ គាត់នៅក្បែរអមលាំងហ្នឹង ។

ដានី៖ កាលនៅស្ទឹងត្រង់អីហ្នឹង កុយ ធួន គាត់នៅជុំជាមួយគ្នាដែរ?

ចៀម៖ អត់ទេ! កុយ ធួន គាត់នៅមន្ទីររបស់គាត់នៅមន្ទីរភូមិភាគ ។

ដានី៖ មន្ទីរភូមិភាគ នៅឯណាទៅ?

ចៀម៖ មន្ទីរភូមិភាគនៅ២៥ ផង នៅគីឡូ១៣ផង ។

ដានី៖ មន្ទីរភូមិភាគនៅក្នុងចំការកៅស៊ូហ្នឹងដែរ?

ចៀម៖ បាទ! ដល់ពេលហៅធ្វើការ គាត់មកធ្វើការទៅ ភូមិភាគ គេនៅតាមភូមិភាគគេទាំងអស់ ដល់ ហៅទៅបានគេមកៗ ។

ដានី៖ ដល់កន្លែងមជ្ឈិមនៅហ្នឹងទៅនៅកន្លែង ប...ដល់ពេលគាត់មកបញ្ជាសមរភូមិនៅខាងអមលាំងខាងអីហ្នឹង មន្ទីរទាំងអស់នៅខាងស្ទឹងត្រង់រើមកទាំងអស់?

ចៀមៈ	អត់ទើរទេ! នៅមួយចំនួន កន្លែងអ្នកប្រចាំការនៅទាំងអស់ ពីព្រោះយើងចល័តកាលហ្នឹង យើង មិនទាន់មាន...ដល់ចេញមកៗ មែនទែនមកនេះកាលហ្នឹង អ៊ីនួន ជា គាត់នាំមក ហ្នឹង ឆ្នាំ១៩៧២ មកដល់សំឡូតនេះ ខ្ញុំមកដល់សំឡូតដែរ ដើរជាមួយអ៊ីនួន ជា កាលនោះ ។

ដានីៈ	ដើរថ្មើរជើងរហូត!

ចៀមៈ	បាទ! ដើរ ។

ដានីៈ	ដើររយៈពេលប៉ុន្មានទៅបានមកដល់សំឡូត?

ចៀមៈ	រយៈពេល៤ខែណុះដើរ

ដានីៈ	កាលហ្នឹងយើងដើរតាមផ្លូវ យើងធ្វើការបណ្តើរ?

ចៀមៈ	បាទ! ដើរតាមមូលដ្ឋាន ធ្វើការបណ្តើរៗ កាលមកពីកំពង់ថ្ម មកស្រុកកំពង់លែងនេះ ចេញពីស្រុកកំពង់លែងទៅឆ្លងមកកំពង់ឆ្នាំងនេះទៅ បានមកអមលាំងហ្នឹង ភ្នំពិស ។ ៧៣ ហ្នឹងបានតា ប៉ុល ពត គាត់ទៅ ទៅបញ្ជាសមរភូមិ ។

ដានីៈ	កាលហ្នឹង តា ប៉ុល ពត តានួន ជា គាត់ដើរជាមួយគ្នា ឬក៏អត់ទេ បែកគ្នាពេលដែលយើង ដើរ តាមមូលដ្ឋានទៅកន្លែងផ្សេងៗ?

ចៀមៈ	ជួនណាអត់ទេ គាត់ដើរអត់ជុំគ្នាទេ ដូចថា តាប៉ុល ពត គាត់ទៅមុនអីចឹង តាប៉ុល ពត គាត់ទៅមុខ តានួន ជា គាត់ប្រចាំការនៅមន្ទីរ កាលគាត់នៅអមលាំង បើគាត់មានការអី គាត់ហៅពិភាក្សាទៅ ។

ដានីៈ	កាលទៅសំឡូត អ៊ំមកជាមួយតានួន ជា កាលហ្នឹងតាប៉ុល ពត គាត់អត់មកទេ?

ចៀមៈ	បាទ! ៧៣ បានគាត់មក ។

ដានីៈ	កាល៧២ គាត់នៅស្ទឹងត្រង់អាឡើយទេ ដល់ឆ្នាំ៧៣ បានគាត់មកអមលាំង?

ចៀមៈ	បាទ!

ដានីៈ	តានួន ជា គាត់មកសំឡូតយូដែរអត់ទេ?

ចៀមៈ	គាត់មកធ្វើការប្រហែលមួយអាទិត្យទេត្រឡប់ទៅវិញ ។

ដានីៈ	ត្រឡប់ទៅអមលាំងវិញ?

ចៀមៈ	បាទ!

ដានីៈ	កាលហ្នឹងសំឡូតមានអីបានគាត់មកធ្វើការ?

ចៀមៈ	មកជួបតា រស់ ញឹម តាគី និងតាគុល កាលហ្នឹងភូមិភាគពាយ័ព្យមានពានាក់ហ្នឹង ។

ដានីៈ	អីចឹងអ៊ំចល័ត មិនមែនតែនិរសាររបស់តាប៉ុល ពត ម្នាក់ទេ?

ចៀមៈ បាទ! ពេលខ្ញុំដើរជាមួយអ៊ីនួន ជា ផង ដើរជាមួយតាប៉ុល ពត.....

ដានីៈ កាលហ្នឹងតាៗ គាត់អីស្គាល់ច្បាស់ម៉ង?

ចៀមៈ ច្បាស់! គាត់អ្នកយកមកតែម្ដង យកមកពីរតនៈគិរី ។

ដានីៈ គាត់មានឲ្យអីរៀនសូត្រអីដែរទេ?

ចៀមៈ រៀនឯកសារ ពេលទំនេររៀនឯកសារទៅ ។

ដានីៈ គាត់បង្រៀន ឬគាត់ឲ្យឯកសារមកមើល?

ចៀមៈ អត់ទេ! មិនមែនគាត់អ្នកបង្រៀនទេ មានអ្នកផ្សេងគេបង្រៀន មានសៀវភៅមានបិចអីណា... ខ្ញុំអាចមើលបាន សរសេរបាន រៀនតាមឯកសារ កាលរៀនខ្ញុំនៅចាំបាន រៀនឯកសារ កាលហ្នឹងសង្គ្រាម ប្រជាជន និងសង្គ្រាមឈ្លប ឯកសារបញ្ជាក់ថាអីចឹង ។

ដានីៈ អ៊ីជាកូនចៅគាត់យកមកផ្ទាល់អីចឹង គាត់មានណែនាំយើងថាម៉េចខ្លះកាលហ្នឹង?

ចៀមៈ រៀនពីរបៀបរបប ដឹកនាំធ្វើការងារហ្នឹងណា យើងធ្វើការងារយ៉ាងម៉េច ត្រូវកសាងខ្លួនយ៉ាងម៉េច ស្អីដែលមិនចំរើនយើងចំចាត់ ស្អីដែលចំរើនយើងកសាងឲ្យរីកចំរើន ទាំងការគិតគូ ទាំងការរស់នៅ រស់នៅឲ្យមានសីលធម៌ល្អ ឲ្យមានគុណធម៌ត្រឹមត្រូវ មានសមត្ថភាពយល់ដឹងជុំវិញខ្លួនយើង ក៏ដូចជុំវិញមិត្តភក្តិ ជុំវិញអ្នកដឹកនាំអីចឹងណា យល់ពីបញ្ហាហ្នឹង ។

ដានីៈ កាលហ្នឹងអ្នកយកអ៊ីមកនៅជាមួយ តាប៉ុល ពត ឬ តានួន ជា ឬក៏អ៊ី អៀង សារី កាលហ្នឹង?

ចៀមៈ ខ្ញុំជួបគាត់ដំបូង ខ្ញុំជួបអ៊ី អៀង សារីទេ ខ្ញុំមកនៅជាមួយអ៊ី អៀង សារី មួយរយៈ ដល់ប៉ុល ពត គាត់មក ពីប៉េកាំង ឆ្នាំ៧០ ខែ៥ ហ្នឹង គាត់យកខ្ញុំមកជាមួយគាត់ហ្នឹង អ៊ីអៀង សារីក៏ឯកភាពដែរ គាត់យកខ្ញុំមកនៅជាមួយគាត់ទៅ តាំងពី ឆ្នាំ៦៧មកស្គាល់ហ្នឹង ។

ដានីៈ ប៉ុន្មាននាក់ទៅដែលតាប៉ុល ពត គាត់យកមកនៅជាមួយ ដូចអ៊ី ដូចថាជនជាតិមកពីរតនៈគិរី?

ចៀមៈ ការពារផ្ទាល់ ២,៣នាក់ដែរ ប៉ុនស្លាប់អស់ហើយ ។

ដានីៈ ពីណាគេខ្លះទៅ?

ចៀមៈ បងកែន ក៏ស្លាប់ ពូហួន ក៏ស្លាប់ ។

ដានីៈ ពួកគាត់ជនជាតិដែរ?

ចៀមៈ អឺ! ផាត ក៏ស្លាប់ ភាត ក៏ស្លាប់ សឹម ក៏ស្លាប់ គី ក៏ស្លាប់ ស្លាប់ច្រើនដែរហ្នឹង ។

ដានីៈ ពួកគាត់សុទ្ធតែជាជនជាតិចរាយ ឬក៏ជនជាតិផ្សេងៗ?

ចៀមៈ ផ្សេងគ្នាទាំងអស់ អត់ដូចទេ ខ្លះចរាយ ខ្លះទំពួន ខ្លះគ្រឹង ខ្លះកាវែត ខ្លះព្រៅ ខ្លះកាចក់ ។

ដានីៈ ប៉ុន្មាននាក់ទៅដែលគាត់យកមកនៅជាមួយ?

ចៀមៈ គ្នា៨០នាក់ ចំរុះតែម្តង ។

ដានីៈ ខ្មែរក៏មាន!

ចៀមៈ បាទ! ខ្មែរក៏មាន គ្រួសារគាត់, ទាវ អ៊ុល, ប៉ីង, បងយ៉ាន, បងសូ ហុង....ខ្មែរកាលហ្នុង មិនដល់១០នាក់ ទេ ។

ដានីៈ សូ ហុង ហ្នុងក្មួយរបស់គាត់ឬ?

ចៀមៈ បាទ! ក្មួយគាត់បង្កើតអីមិនដឹងទេ ដឹងមិនដល់ដែរ កាលហ្នុងអត់ដឹងទេ ទើបតែដឹងក្រោយនេះ ។

ដានីៈ អីចឹងមកដល់ស៊ឹងត្រង់បានជួបអ៊ំនួន ជា?

ចៀមៈ បាទ! មកដល់ស៊ឹងត្រង់បានជួបជុំគ្នាទាំងអស់ នួន ជា, ខៀវ សំផន, ហូ នឹម, ហូ យន់ នៅហ្នុងទាំងអស់ ដល់គ្រប់ភូមិភាគមកធ្វើការ នៅហ្នុងទាំងអស់ ភូមិឧត្តរ ភូមិភាគនិរតី ភូមិភាគពាយ័ព្យ ភូមិភាគបជ្ឈឹម ភូមិភាគពិសេស គ្រប់ទិស និយាយរួមមាកម្តុជាហ្នឹងមកជុំគ្នា ។

ដានីៈ មកជុំគ្នានៅស៊ឹងត្រង់ហ្នឹងទាំងអស់?

ចៀមៈ បាទ! ធ្វើការចប់ ត្រឡប់ទៅវិញតាមរៀងៗខ្លួនទៅ ។

ដានីៈ កាលជំនាន់ហ្នុងគេមកធ្វើការជុំគ្នា ដោយធ្វើរជើង ឬតាមរយៈម៉ូតូ ឡានអី?

ចៀមៈ មិនដឹងគេមកតាមរយៈអីច្បាស់ដែរ ប៉ុន្តែចូលមកមន្ទីរចូលយប់ ចូលមកមន្ទីរដើរមកដែរ ចេញទៅវិញក៏យប់ដែរ ។

ដានីៈ ចូលមកក៏យប់ ចេញទៅវិញក៏យប់ដែរ?

ចៀមៈ បាទ!

ដានីៈ មានអ្នកជូនផ្លូវឬក៏យ៉ាំងម៉េច?

ចៀមៈ មានអ្នកជូនផ្លូវ និរសារជូនផ្លូវ ពីដំណាក់ការទៅដំណាក់ការមួយមានអ្នកជូនផ្លូវ ។

ដានីៈ ប៉ុន្តែពេលដែលធ្វើការ ធ្វើការពេលថ្ងៃទេ?

ចៀមៈ បាទ! ធ្វើការពេលថ្ងៃទេ ។

ដានីៈ ពេលមកដល់ស៊ឹងត្រង់ អ៊ំធ្វើនិរសារតាប៉ុល ពត ផង ធ្វើនិរសារតានួន ជា ផង?

ចៀមៈ បាទ!

ដានី៖	អត់ប្រកាន់ទេ?

ចៀម៖	អត់ប្រកាន់ទេ! ពីនាក់ហ្នឹងដើរជាប់ ភាគច្រើនមកជាមួយអ៊ី ប៉ុល ពត ។

ដានី៖	កាលអ៊ីមកដល់សំឡូតជាមួយ នួន ជា មកធ្វើការជាមួយ តាញឹម តាគី តាគុល ហ្នុង ហើយ បានអ៊ីត្រឡប់មកអមលាំងវិញ?

ចៀម៖	បាទ!

ដានី៖	នៅអមលាំងមន្ទីរនៅកន្លែងណាទៅ?

ចៀម៖	មន្ទីរនៅភ្នំពីស នៅជើងភ្នំពីស ខាងលិចអមលាំង ។

ដានី៖	ចុះកន្លែងពេទ្យមជ្ឈិមអីនៅកន្លែងហ្នុងដែរ ពេទ្យតាជួន ជឿនអី?

ចៀម៖	ហ្នុងហើយ តាជួន ជឿន នៅជិតវ៉ាស្នាប់នោះ នៅភូមិស្តុកគ្រោល ស្តុកគោល ទួលក្រសាំងម៉េចទេ កាលហ្នុង មុំហ្នុងគេហៅភូមិក្តក់តាងំម៉េចទេ ។

ដានី៖	នៅជិតមន្ទីររបស់អ៊ីៗដែរ ឬនៅឆ្ងាយ?

ចៀម៖	នៅជាប់ នៅមុំៗហ្នុងដែរ ។

ដានី៖	ចុះកាលមកនៅអមលាំងហ្នុងក៏មកនៅជុំគ្នាដែរឬ?

ចៀម៖	អត់ទេ! វគ្គមួយហ្នុងមានតែអ៊ី នួន ជា ទេ ដល់អ៊ី នួន ជា គាត់ត្រឡប់ទៅស្ទឹងត្រង់វិញបាន អ៊ីប៉ុល ពត គាត់មកម្តង ។

ដានី៖	ដល់ពេលអ៊ីចល័ត អ៊ី ទៅស្ទឹងត្រង់ផង មកអមលាំងផង ឬក៏នៅតែអមលាំងទេ?

ចៀម៖	ខ្ញុំចល័តដែរ មកអមលាំងផង ទៅស្ទឹងត្រង់ផង ។

ដានី៖	កាលហ្នុងដូចថាអ៊ីដើរតាមតាៗ គាត់ទៅណា អ៊ីទៅតាមគាត់?

ចៀម៖	បាទ!

ដានី៖	អត់ដែរមកនៅខាងកងទ័ពអីទេ?

ចៀម៖	អត់ទេ! កន្លែងបិទវគ្គកងទ័ពហ្នុងទៅ កន្លែងគេមានមន្ទីរគេ មន្ទីរយោធាហ្នុងខ្ញុំទៅបើកវគ្គ ចប់វគ្គក៏មកស្ទឹងត្រង់វិញមក ។ កាលហ្នុងបើកវគ្គមានខាងកងទ័ព ហើយនឹងតាមមូលដ្ឋានតាមភូមិភាគ ។

ដានី៖	អ៊ឹ! ខ្ញុំមើលតាមរូបថតណា ខ្ញុំឃើញ សម្តេចឪ និងសម្តេចម៉ែ ពួកគាត់យាង តាមវៀតណាម យាងចូលមកខាងកម្ពុជាយើង...

ចៀមៈ កាលហ្នឹង វាឆ្នាំ៧៣ ខ្ញុំទៅទទួលនៅសៀមប៉ាំងឯណោះ មកតាមស៊ឹងត្រែងហ្នឹង ទៅបានឆ្លង ស៊ឹងសែន បានទៅឡានទៅភ្នំគូលេន បន្ទាយស្រី ទៅអង្គរវត្ត បានត្រឡប់ទៅវិញ ខ្ញុំទៅអម ដំណើរគាត់ ដែរកាលហ្នឹង ។

ដានីៈ ឆ្នាំ៧៣ ហ្នឹង?

ចៀមៈ ឆ្នាំ៧៣ហ្នឹង អឺអៀង សារី ក៏មកអមដំណើរសម្តេចឪ... ដល់៧៤ គាត់មកជាមួយ អ្នក កាសែតចិន ៧៤ គាត់មកម្តង ។

ដានីៈ គាត់មកតាមណាហ្នឹង?

ចៀមៈ មកតាមស៊ឹងត្រែងហ្នឹង ។

ដានីៈ ពីស្រុកយួន ចូលតាមស៊ឹងត្រែងមក?

ចៀមៈ បាទ!

ដានីៈ មកដល់ណាដែរអ្នកកាសែតចិន?

ចៀមៈ ឆ្នាំ៧៤ មកដល់ក្រុងកែប ។

ដានីៈ អូ! ឆ្នាំ៧៤ចូលដល់ក្រុងកែបដែរ?

ចៀមៈ បាទ! ចូលដល់ក្រុងកែប ។

ដានីៈ ចុះកាលហ្នឹងទាហាន លន់ ណុល អីគេអត់...?

ចៀមៈ អត់ទេ! យើងដើរតាមតំបន់រំដោះ អត់មានបញ្ហាអីទេ ទៅតែកន្លែងទឹកដីយើងរំដោះបាន ហើយ ណា អត់មានប៉ះទេ ទឹករំដោះទូលំទូលាយយើងដើរយ៉ាងស្រួល ។

ដានីៈ ចុះកាលសម្តេចឪ សម្តេចម៉ែយាងមកហ្នឹងមករយៈពេលប៉ុន្មានថ្ងៃទៅ?

ចៀមៈ មកមិនយូប៉ុន្មានទេ មកក្នុងខែ៣កាលហ្នឹង នៅសៀមប៉ាំងដូចជា៣យប់ នៅអន្លុងក្រមួន ដូចជា ៣យប់ដែរ ។

ដានីៈ អន្លុងក្រមួននៅឯណាទៅ?

ចៀមៈ នៅជិតថាឡាបរិវ៉ាត់ហ្នឹង បានមកដល់ស៊ឹងសែនហ្នឹងក៏៣យប់ដែរ ហើយបានមកអូរក្បាល ឈ្លូស មួយយប់ដែរបានឡើងភ្នំគូលេនហ្នឹង នៅភ្នំគូលេនដូចជា៣យប់ដែរ ។

ដានីៈ អូរក្បាលឈ្លូសនៅម្តុំណាទៅ?

ចៀមៈ អូរក្បាលឈ្លូសទៅពីរវៀងមកខាងជើង ផ្លូវចូលមកភ្នំគូលេនណា ផ្លូវកាត់ព្រៃណា ប៉ុនកាល ហ្នឹង តាកុយ ធួន គាត់មកទទួលមានអាឡាន កាត់សង់កាត់ អាឡានកាត់សង់កាត់ទើបអាច បើកបានកាលហ្នឹង ហីយើងសម្តេចមានឡានអាហ្សីបចិន ហីអាឡានកងបួន ហីឡានអាហ្សីល

បើកតែយប់ៗទេ ថ្ងៃអត់ទេ! កាលនោះវាតឹងតែងណាស់ឆ្នាំ៧៣នោះ អាកាំងវាចាក់បេសំបើមណាស់ បើកតែពេលយប់ទេ កាលហ្នឹងវេទនាណាស់ ។

ដានី៖ អីចឹងសម្តេចយាងតែពេលយប់ទេ?

ចៀម៖ បាទ! ធ្វើដំណើរតែពេលយប់តើស ពេលយប់ហ្នឹងបាន កាលនោះឡានវាទៅបុកគល់សំរោងប៉ះឆ្នេញហីនិងអណ្តូតឈាម សម្តេចម៉ែ និងសម្តេចតាផង ។

ដានី៖ ឡានទៅបុកគល់ឈើ!

ចៀម៖ អឺ! ចុះបើកយប់ ហីវាដីខ្សាចផង អីផងណា ។

ដានី៖ ចុះសម្តេចមានបន្ទូលយ៉ាងម៉េចដល់ពេលឈាមអីចឹង?

ចៀម៖ គាត់ថាបានបង្ហូរឈាមលើសមរភូមិ ។

ដានី៖ មកដល់ភ្នំគូលេន ហើយចូលមកដល់សៀមរាបដែរ?

ចៀម៖ ចូលមកដល់អង្គរធំ យើងទើបរំដោះបាន កាលហ្នឹងលន់ ណល់ នៅទីក្រុងសៀមរាបណុះតើស ថៃដន្យថ្ងៃហ្នឹងវាអត់ផ្ទោង អត់អីដែរ ដូចម្យ៉ាងដែរ ផ្តល់សេចក្តីសុខម្យ៉ាងដែរ ។

ដានី៖ ហីសម្តេចយាងវិញតាមផ្លូវដដែលឬក៏?

ចៀម៖ ផ្លូវដដែលត្រឡប់ទៅវិញ ។

ដានី៖ ជិះឡានដដែល ហីក៏យើង?

ចៀម៖ ជិះឡានដដែល ។

ដានី៖ ចុះកាលមានអ្នកអមដំណើរ ដូចថាវៀតណាម ចិន អីដែរអត់?

ចៀម៖ មានចិនខ្លះ វៀតណាមខ្លះ មានមកអមដំណើរ ចិនអ្នកបច្ចេកទេសគេ អ្នកយកពត៌មានអីចឹងណា ខាងវៀតណាមគេក៏អីចឹងដែរ ។

ដានី៖ មានអ្នកដឹកនាំគេមកអមជាមួយដែរអត់?

ចៀម៖ អ្នកដឹកនាំដូចមិនមាន ដូចមិនឃើញគេខ្មែរទ្ធសនាមស្អីផង មានតែខ្មែរទ្ធសនាមសម្តេចឪហ្នឹងអ៊ំអៀង សារី គាត់អ្នកអមដំណើរហ្នឹង ជាបេសកជនពិសេសរបស់អ្នកចលនាគស៊ូហ្នឹង ។

ដានី៖ តាប៉ុល ពត គាត់ទៅដែរ!

ចៀម៖ ទៅ! ទៅទាំងអស់អ្នកដឹកនាំហ្នឹង នួន ជា ក៏ទៅ ខៀវ សំផន, ហូ នឹម ហូ យន់ ទៅទាំងអស់ ។

ដានី៖ សុន សេន អីក៏ទៅដែរ?

ចៀមៈ ទៅ! អ្នកដឹកនាំទៅទាំងអស់ កាលហ្នឹងតាយ៉ា គាត់ទទួល ភូមិភាគឥសាន ក៏គាត់ទៅទទួលដែរ ។

ដានីៈ អីចឹងកាលពួកគាត់មកដល់អមលាំងហ្នឹងនៅរហូតដល់បែកឆ្នាំ៧៩ ឬក៏មានផ្លាស់ទៅណាទៀតដែរអត់?

ចៀមៈ នៅរហូតដល់៧៩រំដោះចូលភ្នំពេញបណ្ដោយ ។

ដានីៈ នៅអមលាំងរហូតដល់ពេល៧៩រំដោះចូលភ្នំពេញ!

ចៀមៈ បាទ! នៅមន្ទីរហ្នឹងតាំងពី៧២មក មន្ទីររបស់ភូមិភាគនិរតីនៅខាងលិចអមលាំង ឯយើងនៅមន្ទីរ ប៥ ជិតភូមិតាំងពូន តាខ្មៅ

ដានីៈ តាំងពូននៅឯណា?

ចៀមៈ តាំងពូនតាខ្មៅនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ដានីៈ នៅហ្នឹងមានតែមន្ទីរប៥ មួយទេ?

ចៀមៈ បាទ! មានតែមួយហ្នឹងទេ ។

ដានីៈ ម៉េចបានដាក់ឈ្មោះ ប៥?

ចៀមៈ មិនដឹងម៉េចដែរ គាត់អ្នកដាក់ប៥ ដាក់តាមគាត់ទៅ ។

ដានីៈ តាណាអ្នកដាក់?

ចៀមៈ តាប៉ុល ពត ។

ដានីៈ ដល់បែកឆ្នាំ៧៩ យ៉ាងម៉េចទៅ?

ចៀមៈ បែកឆ្នាំ៧៩ ចូលភ្នំពេញ ។

ដានីៈ ពេលចូលភ្នំពេញអ៊ំទៅនៅជាមួយគាត់ទៀតឬម៉េច?

ចៀមៈ ចូលភ្នំពេញនៅជាមួយគាត់មួយរយៈ ដល់អ៊ំអៀង សារីមក គាត់ត្រឡប់មកវិញគាត់ត្រូវបង្កើតក្រសួងការបរទេសនោះ ខ្ញុំមកនៅជាមួយអ៊ំ អៀង សារី វិញ ។

ដានីៈ អ៊ំអៀង សារី សុំអ៊ំមកនៅជាមួយគាត់វិញ ឬក៏អ៊ំចង់មកនៅជាមួយអ៊ំអៀង សារី....

ចៀមៈ អត់ទេ! យើងអត់មានសិទ្ធិអីទៅសុំទេ អ៊ំប៉ុល ពត គាត់ចាត់តាំងឲ្យទៅនៅជាមួយអ៊ំអៀង សារី ខ្ញុំក៏មកនៅជាមួយគាត់មក ធ្វើការងារជុំវិញការទទួលភ្ញៀវណា ការងារហ្នឹងវាធ្ងន់ធ្ងរដែរ... រៀបចំផ្ទះសម្បែង រៀបចំទទួលភ្ញៀវណា ។

ដានីៈ ភ្ញៀវមកពីណាកាលហ្នឹង?

ចៀមៈ ភ្ញៀវវគ្គទី១ ភ្ញៀវចិន បន្ទាប់មកប្រទេសនានាទៀតទៅ ដល់៣ឆ្នាំនៅភ្នំពេញហ្នឹងនៅក្រសួងការបរទេស មានទូត មានអីណា ។

ដានីៈ ទូតមានប៉ុន្មានប្រទេសដែរ?

ចៀមៈ ទូតកាលហ្នុងនៅប្រចាំមានប្រមាណជាង១០ប្រទេសដែរ មានចិន វៀតណាម ឡាវ យូហ្គោស្លាវី រូម៉ានី អាល់បានី គុយបា អ្នកមកប្រចាំ ប៉ុនទូតផ្សេងៗទៀតដូចជាទូតកូរ៉េខាងជើងដែរ ។

ដានីៈ ចុះទីម័រ?

ចៀមៈ ទីម័រ ក៏មកដែរ ។

ដានីៈ ចុះថៃ?

ចៀមៈ ថៃកាលហ្នុងដូចជាមិនទាន់មានទេ ។

ដានីៈ អីចឹងកាលបែកដំបូង អ៊ំនៅជាមួយតាប៉ុល ពត មួយរយៈដែរ?

ចៀមៈ ហ្នុងហើយ! ដល់ភ្នំពេញដំបូងនៅជាមួយគាត់ ។

ដានីៈ មកដល់ដំបូងនៅកន្លែងណាទៅ?

ចៀមៈ កាលហ្នុងចូលដំបូងនៅកន្លែងវ៉ារទេះភ្លើង ចេញពីវ៉ារទេះភ្លើងមក បានមកកន្លែងក្រសួងសេដ្ឋកិច្ចហេរញ្ញវត្ថុកាល នៅកន្លែងក្រសួងការពារជាតិយើងរាល់ថ្ងៃហ្នឹង កន្លែងត្រសួងសេដ្ឋកិច្ចនិងហេរញ្ញវត្ថុអាហ្នឹងកាលពីសង្គម ។ ទីស្តីការគណៈរដ្ឋមន្ត្រីយើងរាល់ថ្ងៃហ្នឹង កាលជិតទាន់៣ឆ្នាំយើងដាក់ក្រសួងការបរទេស អាកន្លែងផ្ទះចាស់ឥឡូវគេរើចោលអស់រលីញហ្នុង ឥឡូវធ្វើ២ចិនធ្វើមួយទៀត សម្តេចធ្វើខ្លួនឯងមួយទៀត សម្ពោធថ្ងៃហ្នឹងណា ។

ដានីៈ អីចឹងអ៊ំជាអ្នកទទួលភ្ញៀវបរទេស?

ចៀមៈ ខ្ញុំគ្រាន់តែជាបុគ្គលិកគេទេ ជាអ្នករៀបចំផ្ទះសម្បែង រៀបចំបុគ្គលិកបម្រើភ្ញៀវ រៀបចំផ្ទះបាយ បន្ទប់ទឹកអីហ្នុង... ។

ដានីៈ ចុះមន្ទីរ ៨៧០ នៅម្តុំណាទៅអ៊ំ ខ្ញុំឮតែ៨៧០ ប៉ុន្តែមិនដឹងថានៅម្តុំណា?

ចៀមៈ មន្ទីរ ៨៧០ហ្នុង គេហៅ ក៣ ផង នៅទន្លេបាសាក់នៅកន្លែងទូតស្វីតគេទេ... កន្លែងរួមសហករណ៍របស់មជ្ឈឹមនៅហ្នុងដែរណា ក៣ហ្នឹងគេដាក់មន្ទីរ៨៧០ហើយ ប៉ុនវាចល័តកាលហ្នុងណា ពេលខ្លះនៅវាំងនៅជាប់វាំង ក្បែរវត្តព្រះគោព្រះកែវ អាហ្នុងក៏នៅដែរ ។

ដានីៈ កន្លែងជិតពេទ្យគន្ធបុប្ផាហ្នុងឬ?

ចៀមៈ បាទ!

ដានី៖ មន្ទីរ៨៧០ហ្នឹងចល័តទេអីចឹង?

ចៀម៖ បាទ! ចល័តតើ នៅជិតមន្ទីរពេទ្យហ្នឹងក៏នៅ នៅមាត់ទន្លេបាសាក់ហ្នឹងក៏នៅ នៅតាខ្មៅហ្នឹងក៏នៅ នៅប្រាំចំរេះនោះក៏នៅ ។

ដានី៖ អីចឹង ដូចថា មន្ទីរ៨៧០ មន្ទីរក៣ សម្រាប់គាៗគាត់ធ្វើការ?

ចៀម៖ បាទ!

ដានី៖ ប៉ុន្តែក្រៅពីមន្ទីរ៨៧០ តា ប៉ុល ពត គាត់ស្នាក់នៅម្តុំណាទៅ នៅក្រៅពីមន្ទីរ ៨៧០ មន្ទីរ ក៣ អីហ្នុង?

ចៀម៖ គាត់នៅចល័តតាមហ្នឹងដែរ ជួនណានៅក៣ ជួនណានៅជិតវាំង ជួនណានៅជិតទន្លេបាសាក់ អីចឹងទៅ ជួនណាចេញទៅតាមភូមិភាគ ។

ដានី៖ តានួន ជា ក៏អីចឹងដែរ?

ចៀម៖ បាទ! ចល័ត ។

ដានី៖ ខៀវ សំផន!

ចៀម៖ ចល័តដែរ ។

ដានី៖ អីចឹងអីនៅកន្លែងទទួលភ្ញៀវ នៅក្រសួងការបរទេស (ទីស្តីការគណរដ្ឋមន្ត្រីសព្វថ្ងៃ)?

ចៀម៖ បាទ!

ដានី៖ អឹស្នាក់នៅកន្លែងហ្នុងបណ្តោយ!

ចៀម៖ ខ្ញុំកន្លែងក្រសួងនៅហ្នុង ប៉ុន្តផ្ទះនៅជិតម៉ាជួរក្រសួងហេរិញ្ញវត្ថុរាល់ថ្ងៃ នៅកន្លែងអភិវឌ្ឍន៍កម្ពុជា (ស៊ីឌីស៊ី) នៅជិតវត្តភ្នំ កន្លែងទទួលភ្ញៀវធំនៅហ្នុង ហើយនិងនៅចំការមនណុះ ។

ដានី៖ ទទួលភ្ញៀវហ្នុងយ៉ាងម៉េច យើងរៀនចំផ្ទះសម្បែង ម្ហូបអាហារឲ្យគេ?

ចៀម៖ បាទ! រៀបចំកន្លែងឲ្យគេរស់នៅមានទឹក មានអីចឹងទៅ ។

ដានី៖ ចុះពួកនិស្សិតដែលរៀននៅក្រៅប្រទេស ដែលគាត់មកអីចឹងយើងឲ្យគាត់នៅអីយ៉ាងម៉េច អីជីងទេ?

ចៀម៖ ពួកនិស្សិតកាលហ្នឹងភាគច្រើនមកពីក្រៅប្រទេសនៅបឹងត្របែក ចេញពីហ្នុងមកទើបមកធ្វើការនៅក្រសួងការបរទេស ស្រង់ចេញពីហ្នុងមកធ្វើការក្រសួងការបរទេស ដូចបងសេង ហុង ក៏មកពីហ្នុង បង ហោណាំហុង ក៏មកពីហ្នុងដែរ ស្គាល់គ្នាតើស ។

ដានី៖ គាត់ធ្វើអីដែរ?

ចៀមៈ កាលហ្នឹងគាត់ទើបមកនៅក្រសួង គាត់ជួយខាងការងារខាងនយោបាយ បង គាត ឈន់ អី នោះ ។

ដានីៈ គាត់ធ្វើនៅក្រសួងការបរទេសដែរ?

ចៀមៈ បាទ! បង អ៊ុក សុគន្ធ នៅបារាំង ប៉ុនគាត់ស្លាប់ហើយ សុទ្ធតែបងៗបញ្ញាជន ជួន ប្រាសិទ្ធ អីនៅ ហ្នឹងដែរ ឥឡូវគាត់នៅបារាំងណុះ ។

ដានីៈ ពួកគាត់និស្សិតមកពេលហ្នឹងដែរ ឬក៏គាត់អ្នកតស៊ូមុនហ្នឹងទៀត?

ចៀមៈ គាត់មុនហ្នឹងខ្លះឃើញតាំងពីឆ្នាំ៧០ និស្សិតដែលមកធ្វើការជាមួយអ៊ីអៀង សារី តាំងជំនាន់សម្តេចឪ តាំងពីជំនាន់ឆ្នាំ៧០ម្ល៉េះ និស្សិតនៅខាងក្រៅចូលមកហែរៗរហូត ។

ដានីៈ នៅក្រសួងការបរទេស អ៊ីអៀង សារី គាត់ទទួលខុសត្រូវរួម?

ចៀមៈ បាទ!

ដានីៈ ចុះបន្ទាប់ពីគាត់?

ចៀមៈ បន្ទាប់ពីគាត់ បងសូ ហុង ។

ដានីៈ ចុះវ៉ាន់ ពីនី?

ចៀមៈ វ៉ាន់ ពីនី ខ្ញុំ អត់ស្គាល់ឈ្មោះហ្នឹងផង ។ ឈ្មោះបដិវត្តន៍ឈ្មោះអី?

ដានីៈ គាត់នៅបន្ទាប់ៗដែរ គេចាប់គាត់ណា!

ចៀមៈ វ៉ាន់ ពីនី!នៅក្នុងក្រសួង អ៊ីអៀង សារី, សូ ហុង គាត់ទទួលខុសត្រូវរួម រៀបចំខាងផ្នែកនយោបាយ មានបង ទីប...បង គាត ឈន់ បងសុគន្ធ, ចាន់យូរ៉ាន់ ដែរ អ៊ិន សុភាព, ឡុង នូរិន...ប៉ុនហេង បងទិត សំណាង ។

ដានីៈ ចុះ ប៉ាង ដែលអ៊ីមានប្រសាសន៍ថាដែលមកពីលើជាមួយហ្នុង គាត់នៅឯណាដែរ?

ចៀមៈ គាត់នៅ ៨៧០ គាត់ប្រធានមន្ទីរ ៨៧០ ។

ដានីៈ ចុះ ខឿន?

ចៀមៈ ទូច ខាំខឿន នៅក្រសួងការបរទេស ដែរតើស ។

ដានីៈ ខ្ញុំមើលឯកសារទៅឃើញទូច ខាំខឿន ហ្នឹងដូចនៅជាមួយប៉ាង?

ចៀមៈ តូចខាំខឿន បងបង្អូនរបស់តូច ភឿន រដ្ឋមន្ត្រីខាងគមនាគមន៍ ។

ដានីៈ អ៊ីជនជាតិ មកនៅក្រសួងការបរទេស តែម្នាក់ឯង ឬក៏មានអ្នកផ្សេងទៀតដែរ?

ចៀមៈ មានម្នាក់ទៀត ហៅមិត្ត ទួនៗ ឥឡូវគាត់នៅកញ្ចាប់ ។

ដានីៈ នៅឯណាកញ្ចាប់ហ្នឹង?

ចៀមៈ កញ្ចាប់នៅខេត្តប៉ៃលិន ។

ដានីៈ ស្រុកអីគេ កញ្ចាប់?

ចៀមៈ ដូចមិនដឹងទេ!

ដានីៈ គាត់ឈ្មោះអីឥឡូវហ្នឹង?

ចៀមៈ ឥឡូវគេដាក់ឈ្មោះ ទូ! ពីមុនគាត់ឈ្មោះ ទូន ឥឡូវគេហៅ ទូ ។

ដានីៈ គាត់នៅក្រសួងការបរទេសដែរ?

ចៀមៈ កាលហ្នឹងគាត់ទទួលខាងបច្ចេកទេសនៅទូតកូរេខាងជើង បច្ចេកទេសខាងចិនដែរ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអី?

ចៀមៈ ឈ្មោះ ជឿន ។

ដានីៈ តែ២នាក់ហ្នឹងទេនៅក្រសួងការបរទេស?

ចៀមៈ បាទ!

ដានីៈ ចុះអ៊ំ! ដូចថាយើងធ្លាប់តែតស៊ូអីចឹង ដល់មកទទួលភ្ញៀវយើងពីបាកម៉េចដែរ ដូចថាយើងមិន ដែរធ្លាប់ធ្វើការខាងទទួលភ្ញៀវទទួលអីហ្នឹង?

ចៀមៈ អ៊ឹៗ គាត់ចេះតែណែនាំ មានបងៗបញ្ញាជនមួយចំនួនហ្នឹងណា បង ឡុង នូរិន គាត់យល់បញ្ហាហ្នឹងតាមគាត់ទៅ ធ្វើនេះធ្វើនោះ រៀនសូត្រមួយរយៈចេះហើយ ។

ដានីៈ រៀនតាមបងៈបញ្ញាជនហ្នឹង!

ចៀមៈ បាទ! កាលហ្នឹងបន្ទប់រៀបចំយ៉ាងម៉េច បន្ទប់ដេករៀបចំយ៉ាងម៉េច បន្ទប់ទឹករៀនចំយ៉ាងម៉េច បន្ទប់ធ្វើការរៀបចំយ៉ាងម៉េច រៀនទៅចេះហើយ ។

ដានីៈ កាលហ្នឹងនៅទទួលភ្ញៀវជាមួយអ៊ំមាន ឡុង នរិន ដែរ?

ចៀមៈ បាទ!

ដានីៈ កាលហ្នឹង ឡុង នរិន អ៊ំ ហើពីណាទៀត?

ចៀមៈ កាលហ្នឹងច្រើនតើស មានបង សួង ស៊ីគឿន ធ្លាប់ស្គាល់គាត់ទេ នៅភ្នំពេញហ្នឹង គាត់ឈឺ ។

ដានីៈ ខ្ញុំធ្លាប់ទៅដល់ស្រុកកំណើតរបស់គាត់នៅខាងព្រែកប្រសប់ ទៅផ្ទះកំណើតរបស់គាត់ ហើយជួបក្មួយគាត់កាលពី ២ ឬ ៣ ឆ្នាំមុន សួរទៅថាគាត់នៅម៉ាឡៃហ្នឹង គាត់បង្រៀនភាសាអង់គ្លេសបង្រៀនអីក្មេងៗ ។

ចៀមៈ បាទ! ប៉ុនសុខភាពគាត់យ៉ាប់!

ដានីៈ ឥឡូវគាត់ទៅនៅភ្នំពេញហើយ?

ចៀមៈ បាទ! គាត់មានក្មួយគាត់នៅជួយមើល នៅភ្នំពេញវាជិតពេទ្យ ជិតអីង៉ាយស្រួល ផ្ទះគាត់នៅ ណោះទុកចោល ។

ដានីៈ ចុះអ៊ីមានប្រពន្ធឆ្នាំណាទៅ?

ចៀមៈ ខ្ញុំការតាំងពីឆ្នាំ៧២ ។

ដានីៈ តាំងពីអ៊ីនៅស៊ឹងត្រង់?

ចៀមៈ បាទ! តាំងពីខ្ញុំនៅស៊ឹងត្រង់ រៀបការនៅស៊ឹងត្រង់ ។

ដានីៈ កាលហ្នុងអ៊ីអាយុប៉ុន្មាន?

ចៀមៈ កាលហ្នុងខ្ញុំអាយុ២៧ ។

ដានីៈ កាលហ្នុងអ៊ីស្រីគាត់ធ្វើអីទៅ?

ចៀមៈ កាលហ្នុងគាត់ធ្វើយុវនារី គាត់នៅខាងមន្ទីរ៣០៤ ។

ដានីៈ គាត់នៅជាមួយ កុយ ធួន!

ចៀមៈ បាទ!

ដានីៈ ចុះរៀបការហើយ គាត់មកនៅជាមួយអ៊ី ឬយ៉ាងម៉េច?

ចៀមៈ កាលហ្នុងគាត់នៅមន្ទីរ៣០៤ ដល់ការហើយគាត់មកនៅរផ្នត់ខាងមន្ទីរ ៨៧០វិញ ។

ដានីៈ គាត់ធ្វើអីនៅមន្ទីរ ៨៧០?

ចៀមៈ ដាំបាយឲ្យតាៗ ។

ដានីៈ ដាំបាយឲ្យតាប៉ុល ពត តា នួន ជា អីហ្នឹង?

ចៀមៈ បាទ!

ដានីៈ គាត់ដាំបាយឲ្យតាៗ រហូតដល់ពេលណាទៅ?

ចៀមៈ ដាំបាយរហូតដល់ឆ្នាំ៧៨ ។

ដានីៈ អីចឹងមកដល់ទីក្រុងភ្នំពេញ ក៏គាត់នៅដាំបាយឲ្យតាៗដែរ?

ចៀមៈ បាទ!

ដានីៈ អីចឹងតាៗ គាត់ពិសារបាយជុំគ្នា?

ចៀមៈ ហ្នឹងហើយ ជុំគ្នា ។

ដានីៈ ចុះផ្ទះគាត់នៅរួមគ្នា ឬនៅបែកគ្នា?

ចៀមៈ ផ្ទះនោះ កន្លែងនោះ ផ្ទះល្វែង វាវែង មានបន្ទប់ៗអីចឹង គាត់នៅតាមហ្នឹងទៅ ។

ដានី៖ អីចឹងនៅក្នុងមន្ទីរ៨៧០ហ្នឹង គាត់ដាំបាយរួមហូបជុំគ្នា ហើយបានគាត់ទៅតាមបន្ទប់រៀងៗខ្លួន?

ចៀម៖ បាទ! នៅមន្ទីរ ៨៧០ មានសហករណ៍ធំមួយ ថ្នាក់ដឹកនាំទាំងអស់នៅហ្នឹងដល់ពេលហូបបាយជុំគ្នា ព្រឹកហូបបបរជុំគ្នា ថ្ងៃ ត្រង់មកពីធ្វើការវិញហូបបាយជុំគ្នា ល្ងាចក៏អីចឹងដែរ ជុំកន្លែងសហករណ៍មួយធំ ដូនណាអ៊ឹម អៀង សារី នៅកន្លែងមន្ទីរប១ក្រសួង គាត់មកហូបបាយជាមួយពួកខ្ញុំដែរហ្នឹង ហូបបាយកន្លែងក្រសួងហ្នឹងណា សហករណ៍នៅក្រសួងហ្នឹង ។

ដានី៖ នៅ ៨៧០ហ្នឹង?

ចៀម៖ អត់ទេ! នៅក្រសួងការបរទេសណា ពួកខ្ញុំហ្នឹង ។

ដានី៖ គាត់ហូបបាយជាមួយដែរ?

ចៀម៖ បាទ!

ដានី៖ អីចឹងអ៊ឹ នៅកន្លែងប១ហ្នឹងហូបបាយរួមជុំគ្នា?

ចៀម៖ បាទ!

ដានី៖ ចុះអ៊ឹ អៀង សារី គាត់មកហូបបាយជុំជាមួយរាល់ថ្ងៃ ឬដោយពេលទេ?

ចៀម៖ គាត់ដោយពេលទេ កន្លែងសហករណ៍គាត់ជាមូលដ្ឋាន ប៉ុនគាត់ធ្វើការជាមួយក្រសួងហ្នឹង គាត់ហូបហ្នឹងខ្លះ ។

ដានី៖ ពេលហូបចុកអីចឹងយ៉ាងម៉េចដែរ កាលហ្នឹងយើងហូប៣ពេល ដូចថាព្រឹកបបរ ថ្ងៃត្រង់បាយ ល្ងាចបាយ?

ចៀម៖ បាទ!

ដានី៖ ចុះម្ហូបអីយ៉ាងម៉េចទៅ?

ចៀម៖ ហូបមានសម្លម្ជូរ មានឆារ មានចៀនត្រីអីចឹងទៅ ។

ដានី៖ មួយពេលប៉ុន្មានមុខទៅពេលហូបម្ដងៗ?

ចៀម៖ ៣មុខ មិនហួស៣មុខទេ ២មុខ ទៅ៣មុខ សម្លទឹកមួយទៅ សម្លបន្លែមួយ សាច់អីមួយទៀតទៅណា គ្រប់៣ៗអីចឹងទៅណា ។

ដានី៖ ចុះព្រឹកព្រលឹមឡើងបបរ រាល់ថ្ងៃបបរ?

ចៀម៖ បាទ!

ដានី៖ បបរហូបជាមួយស្អីទៅ?

ចៀមៈ ហូបជាមួយត្រីងៀត ជាមួយពងទាប្រៃ ជាមួយសាច់ត្រី ជាមួយត្រីខ យើងខត្រី ខសាច់ជ្រូក ខគោអីចឹងទៅណា ។

ដានីៈ ចុះមានបន្លែម មានផ្លែឈើអីទេ?

ចៀមៈ មានតើស! មាន! កន្លែងម្ហូបអាហារកន្លែងផ្សារថ្មីរាល់ថ្ងៃ ជាកន្លែងគ្រប់ក្រសួងគេទៅយក នៅ កន្លែងហ្នឹង ផ្លែឈើ ផ្សារហ្នឹង ។

ដានីៈ ផ្សារថ្មីហ្នឹង?

ចៀមៈ កន្លែងហ្នុងគេហៅផ្សាររដ្ឋកាលហ្នុង ខាងពាណិជ្ជកម្មគេទទួលខុសត្រូវ ខាងក្រសួងណាត្រូវការ ទៅ យកនៅកន្លែងហ្នុងទាំងអស់ ឆ្នាំដំបូងអីចឹង ហើយដល់ឆ្នាំទី២ ទី៣ តាមក្រសួងគេម្ចាស់ការ ខ្លួនគេបណ្តើរៗហើយ ដូចជាត្រីសាច់អីគេទៅយកកន្លែងឆ្នុក កន្លែងរាំងព្រលទៅណា ធ្វើ ប្រហុក ធ្វើផ្អក ធ្វើត្រីងៀត អីចឹងទៅ ដាំបន្លែ ដាំអីទៅ ។

ដានីៈ ចុះរបស់របរហ្នឹងមានយកមកពីខាងតំបន់ ខាងភូមិភាគ?

ចៀមៈ តាមកន្លែងគេហ្នឹង គេផ្តល់មកឲ្យ កាលហ្នុងគេមានចាត់មនុស្សឲ្យដាំបន្លែដែរ ដូចនៅច្រាំចំរេះ ដូចនៅព្រែកព្នៅអីចឹង ។

ដានីៈ កាលហ្នុងតាៗ ដូចជាតាប៉ុល ពត តានួន ជា គាត់ខស្សព្រាហ៍ចុះទៅ តាមភូមិភាគ តាមតំបន់ ដែរ?

ចៀមៈ ចុះដែរតើស!

ដានីៈ ចុះញឹកញាប់ដែរ?

ចៀមៈ ញឹកញាប់ដែរតើស ។

ដានីៈ ចុះអ៊ឹង អៀង សារី គាត់ចុះដែរទេ?

ចៀមៈ អ៊ឹង អៀង សារី គាត់អត់សូវមានពេល គាត់ច្រើនទៅក្រៅប្រទេស បើទំនេរគាត់ចុះដែរ ដូចថា គាត់ចុះអមទូត អមគណៈប្រតិភូសំខាន់ៗគាត់ទៅ ។

ដានីៈ អ៊ឹធ្លាប់អញ្ជើញទៅជាមួយពួកគាត់ដែរ?

ចៀមៈ ទៅតើស! មិនដែលខានទេ មកណាទៅណា ទៅជាប់ ។

ដានីៈ ឲ្យតែភ្ញៀវទៅ អ៊ឹទៅជាមួយពួកគាត់ដែរ?

ចៀមៈ បាទ! កាលនៅក្រសួងការបរទេសហ្នុងជាប់ជាមួយអ៊ឹង អៀង សារី ទៅណាមកជាប់ជាមួយ គាត់ ។

ដានីៈ អ៊ឹ អៀង សារី ទៅណា អ៊ឹទៅជាមួយគាត់?

ចៀមៈ បាទ!

ដានីៈ ចុះទៅគ្រប់ភូមិភាគ?

ចៀមៈ បាទ!

ដានីៈ ដូចថាមានការអីត្រូវចុះ គាត់ប្រាប់មកអីថាទៅណាៗ គាត់ប្រាប់មុន?

ចៀមៈ បាទ!

ដានីៈ ចុះគាត់មានធ្លាប់ទៅជួបពួកនិស្សិតអី?

ចៀមៈ ទៅជួបតើស និស្សិតនៅបឹងត្របែក គាត់ទៅជួបខ្ញុំក៏ទៅដែរ ។

ដានីៈ គាត់ទៅជួបប្រាប់និស្សិតថាម៉េច ដូចថានិស្សិតរៀនចប់មកពីបរទេសមកវិញ?

ចៀមៈ គាត់នៃទៅជួបគេនោះ ទី១គាត់ជម្រាប់សភាពការណ៍រួម សភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស ហ៊ីទិសដៅរបស់យើងត្រូវធ្វើអីៗនោះណា ដូចថាយើងមករបបហ្នឹងយើងត្រូវកសាងខ្លួនទៅតាមចលនាដាក់ស្តែង ។

ដានីៈ និស្សិតច្រើនទេកាលហ្នុង?

ចៀមៈ ច្រើនតើស!

ដានីៈ មកពីប្រទេសណាខ្លះទៅ?

ចៀមៈ មកពីគ្រប់ប្រទេស មកពីបារាំង មកពី...

ដានីៈ មានស្រី មានប្រុស?

ចៀមៈ មានតើស! ប៉ុនមកពីបារាំងច្រើនជាងគេ ។

ដានីៈ គាត់ខស្សាហ៍ទៅកន្លែងហ្នុង បើតាមអីចាំ?

ចៀមៈ អត់ទេ! មន្ទីរនោះគេប្រគល់ឲ្យក្រសួងការបរទេសគ្រប់គ្រង ចុង៧៨ហើយហ្នុង ។

ដានីៈ កាលមុនពីណាគ្រប់គ្រង?

ចៀមៈ កាលមុនមន្ទីរ ៨៧០ទេ ហើយបានក្រសួងការបរទេសអ្នកគ្រប់គ្រង ។

ដានីៈ ហោ ណាំហុង អីស្គាល់គាត់តាំងសម័យនោះមកដែរ?

ចៀមៈ បាទ!

ដានីៈ គាត់អ្នកនៅបឹងត្របែកហ្នុងដែរ?

ចៀមៈ បាទ!

ដានីៈ គាត់ធ្វើអីកាលហ្នុង?

ចៀម៖ គាត់គ្រប់គ្រងបញ្ញាជននៅហ្នឹង គាត់បញ្ញាជនដែរ គ្រប់គ្រង់និស្សិតដែរណា បងហេង អុន នៅជាមួយគាត់ ហីបង១ក្រៅពីហ្នឹងមកនៅក្រសួងអស់ហើយ នៅក្រសួងការបរទេស បងញ្ញាជនដូចគ្នា ជួន ប្រាសិទ្ធ គាត ឈន់ អីនៅក្រសួងហើយ ចាន់ យូរ៉ាន់ បងអ៊ិត សុគន្ធ ...

ដានី៖ ចុះអ៊ំមានកម្មាភិបាលមួយចំនួនដែលត្រូវចាប់អី អ៊ំដឹងរឿងហ្នឹងដែរ កាលហ្នុង ប៉ងអីគេចាប់ដែរកាលហ្នុង?

ចៀម៖ គេចាប់! តែបាត់ខ្លួនដឹងហើយបានយើងដឹងថាគេចាប់ ។

ដានី៖ អ៊ំដឹងពីមូលហេតុដែលគេចាប់ដែរទេ?

ចៀម៖ មិនដឹងដែរ!

ដានី៖ កាលហ្នុងដូចថាតស៊ូជាមួយគ្នា ពីជំនាន់តស៊ូអី ក្រោយមកដូចថាមានម៉ាចំនួនត្រូវបាត់ខ្លួនចាប់ កាលហ្នុងមាន វ៉ន វេត, តូច ខាំឌឿន តូច ភឿន, ម៉ាចំនួនទៀតដូច យ៉ា កាលហ្នុងអ៊ំដឹងពីមូលហេតុអីទេ បានគេចាប់ហ្នុងទេ?

ចៀម៖ ដូចថាអារឿងចាប់ហ្នុង វាថាក្បាក់ផ្តើលទាំងអស់ហើយ ដូចថាបាត់អ្នកនេះ បាត់អ្នកនោះក្បាក់ផ្តើលណា ធ្លាប់ធ្វើការជាមួយគ្នា ធ្លាប់ហូបចុកជាមួយគ្នា អាក្រក់ល្អជាមួយគ្នា ទៅជារឿងអីចឹង គិតច្រើនដែរ ។

ដានី៖ តែ តា១គាត់មាននិយាយពីរឿងហ្នឹង អ៊ំដឹងដែរ ដូចថាតា១គាត់ថាពីមូលហេតុម៉េច១?

ចៀម៖ មិនដឹងទេ! អត់មាននិយាយអីផង និយាយពីរឿង កុយ ធួន ខ្ញុំដឹង ដូចថាគេចាប់ អាហ្នឹងគេចុះក្នុងទង់បដិវត្តន៍ណា ដូចថាគាត់ខិលខូចរឿងសីលធម៌អីណា ដូចថាគាត់សារភាពហើយថាគាត់ខុសអាហ្នឹងដឹង ក្រៅពីហ្នឹងអត់ដឹងអីទេ ស្រាប់តែបាត់១ទៅ ។

ដានី៖ បាត់ច្រើនកាលហ្នុងអ៊ំ?

ចៀម៖ បាត់ច្រើនណាស់ បាត់កម្មាភិបាលម៉ាគ្រប់ភូមិភាគ ថ្នាក់កម្មាភិបាលគ្រប់ភូមិភាគ តាមតំបន់ក៏បាត់ តាមស្រុកមួយចំនួនក៏បាត់ បាត់បេះតែប្លែក១ ។

ដានី៖ តាមខ្ញុំដឹង ដូចថាធ្លាប់ជួបអ៊ំ១ ពូមីងមួយច្រើន ដូចថាតាមភូមិភាគ ដូចថាជំនាន់ហ្នុងខាងនិរតីខាងតាម៉ុតហ្នឹង ដល់ក្រោយមកពួកខាងតាម៉ុកគាត់ទៅគ្រប់គ្រងច្រើនខាងពាយ័ព្យ ខាងតាញឹម ខាងបូព៌ា ខាងឧត្តរអី ខាងតាម៉ុក ទៅគ្រប់គ្រង់ច្រើន កាលហ្នុងអ៊ំដឹងពីមូលហេតុហ្នឹងដែរទេ?

ចៀមៈ ខ្ញុំដឹង! គឺថាដល់យកកម្មាភិបាលពីនិរតីគ្រប់គ្រង់ ភូមិភាគផ្សេងៗអាហ្នុងការកាប់សម្លាប់កាន់តែខ្លាំងជាងអ្វីទាំងអស់ ដូចថាពួកហ្នឹងមានវាមោទនភាពណាស់ អ្នកខ្លះតាំងពីជំនាន់នោះវាមិនធ្វើអីផង ដូចថាចរិកខ្មែរយើង គឺថាកាប់គ្នាទៅវិញទៅមក ពួកហ្នឹងវាអាក្រក់! តាម៉ុកហ្នុងអាក្រក់ ខ្ញុំអត់ឯកភាពដែរ ស្អប់ម៉ង កាលមួយរយៈហ្នុងក្នុង៧៩ កាលហ្នុងចង់ទំនាស់គ្នារវាងនិរតីហ្នុង គ្រប់ភូមិភាគចង់មានទំនាស់ជាមួយនិរតីដល់ខ្លាំង ទំនាស់ជាមួយតាម៉ុកហ្នុង កសាងកម្មាភិបាលសម្លាប់គេវាច្រើន ។

ដានីៈ ចុះតាៗ ដូចថាតាប៉ុល ពត តានួន ជា ពួកគាត់មាននិយាយអីទេ?

ចៀមៈ ដូចមិនចាប់អារម្មណ៍ ដូចមិននិយាយអីផង បើនិយាយក្នុងឯកសារអត់សោះ ក្នុងឯកសារមិនមានចែងថាសម្លាប់អ្នកនេះ សម្លាប់អ្នកនោះអត់ទេ យើងតស៊ូធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ... ដល់យើងរំដោះហើយ រំដោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រំដោះហើយបានគេហៅថាធ្វើបដិវត្តន៍សង្គមនិយម ដើម្បីឈានទៅកុម្មុយនិស្តនិយម ឃើញថាទិសដៅអីចឹងៗទេ យើងគិតថាកាលតស៊ូប្រជាជាតិ គឺយើងវ៉ៃចក្រពត្តិអាមេរិក និងបរិវារ វាអីចឹងហើយ ប្រជាធិបតេយ្យ គឺវ៉ៃរបបសក្តិភូមិ និង នាយទុន ប្រតិកិរិយាអាហ្នឹងមានហើយ គេហៅវ៉ៃជារបប មិនមែនវ៉ៃជាបុគ្គលទេ ប៉ុន្តែអនុវត្តន៍ជ្រុល វាទៅជាប៉ះពាល់ដល់អាយុជីវិតគេ គឺខ្លាចៗ កាលហ្នុងដល់ដំណាក់កាលមួយ ទាំងខ្ញុំ ទាំងគេភ័យទាំងអស់ បើឃ្លួនមិនចូលស្រុក ខ្ញុំមិនបាននៅទេ បើតាមមើល មិនស្រួលគេចាប់ដែរហើយ ។

ដានីៈ ម៉េចអីចឹង?

ចៀមៈ ដឹង! វាមិនដឹងម៉េចដែរ ។

ដានីៈ ដូចថាតាំងពីដើមមក អ៊ំនៅជាមួយតាៗ ដូចថានៅជាមួយតាប៉ុល ពត អៀង សារី តានួន ជា នៅអីចឹងហើយអ៊ំខ្លាចដែរ អ៊ំចូលមកដំបូងមកជាមួយគាត់ហើយហ្នឹង?

ចៀមៈ ដល់គេខុទ្ទេសនាមគាត់ជាអ្នកដឹកនាំដូចអត់ខ្លាចអីទេ ដូចតាំងពីធ្វើមកដល់រំដោះភ្នំពេញ ឃើញចលនាដូចទឹកបាក់ទំនប់អីចឹង ខ្លាំងណាស់! ក្រោយរំដោះឃើញថាដណ្តើមអំណាចគ្នា តែម្តងគិតទៅ ។

ដានីៈ ពីណាដណ្តើមពីណា?

ចៀមៈ ដណ្តើមអំណាចគ្នាអាក្រក់ណាស់ តាម៉ុក ហ្នុងអាក្រក់ជាងគេ ខ្ញុំឃើញជាក់ស្តែងហ្នឹង តាម៉ុកអាក្រក់ជាងគេ ហេតុអីបានខ្ញុំនិយាយថាអាក្រក់ជាគេ ពីព្រោះអារំដោះភ្នំពេញហ្នឹងណា

ឈ្មោះគ្នាពេលស៊ីបាយ ឈ្មោះគ្នា ថាមិត្ត សោ ភឹម ហ្នឹងគ្មានទៅដល់មុនគេឯណាទេ កុយធួន គ្មានទៅដល់មុនគេឯណាទេ មិត្តខៀវ (សុន សេន) គ្មានទៅដល់មុនឯណាទេ មានតែតាម៉ុកទេបានទៅដល់មុនគេ រំដោះភ្នំពេញនោះ ហឺប៉ុល ពត គាត់ចេះតែសំរួលថាយើងសាមគ្គីគ្នាទៅ រំដោះភ្នំពេញនោះ មិនមែនតែកម្លាំងណាមួយបានទេ ទល់តែរួបរួមសាមគ្គីគ្នាបានយើងរំដោះ គាត់នៅតែប្រជែងប្រជ៉ាំងជាងគេម៉ង អាមនុស្សហ្នឹង ។

ដានី: តាម៉ុកហ្នឹង!

ចៀម: ហ្នឹងហើយ!

ដានី: ពេលប្រជុំពួកគាត់និយាយរឿងហ្នឹង?

ចៀម: ហ្នឹងហើយ! និយាយខុសគេ ខុសឯងម៉ង... និយាយរឿងគំនុំស្អាប់រស់ជាមួយគាត់ បានវាងាប់បាត់អីចឹងក៏វាម្យ៉ាងដែរ ស្អប់ម៉ង ។

ដានី: អឹស្អប់គាត់ដែរ!

ចៀម: អាមនុស្សអាក្រក់ពេក...

ដានី: អីចឹងពេលពួកគាត់មកប្រជុំអីនៅ៨៧០ អឹធ្លាប់ឃើញ ធ្លាប់ឮ...?

ចៀម: ឃើញ!... ខ្ញុំនៅហ្នុងដែរ ប៉ុនខ្ញុំកាលពាឆ្នាំ ខ្ញុំអត់ដែលកាន់យោធាសោះ ខ្ញុំអត់ដឹងទេ ប៉ុនកាល ដល់៧៩នេះ បានខ្ញុំឃើញ រកវៃខ្ញុំ ខ្ញុំវៃវិញមើល អត់ខ្លាចទេម៉ុកឯង គាត់ដេរឈ្មោះជាមួយខ្ញុំ គាត់ដាក់កាំភ្លើងបាញ់ ខ្ញុំបាញ់ទៅវិញ កាលហ្នុងមិនហ៊ានធ្វើខ្ញុំដែរ ខ្ញុំមានកម្លាំងដែរ កាលនៅខត្តរ កាលនៅអន្លង់វែង មនុស្សនេះអាក្រក់ណាស់ អូ!ល្មមៗជាន់គេមើលងាយម៉ង យើងជនជាតិអីចឹងមើលងាយម៉ង អាក្រក់ណាស់ មិនចូលចិត្តទេអាមនុស្សអីចឹង បានវាងាប់បាត់ទៅ ក្តៅក្រហាយណាស់ ដោយសារអាតាម៉ុកហ្នុងបានវាខូច សភាពការណ៍នោះកុំតាម៉ុកហ្នុងវាមិនដល់ថ្នាក់ហ្នឹងពេកដែរ កាលពីដើម... ត្រឹមរ៉ាកន្ត្រក តែស្អុយមួយស្អុយទាំងអស់ហើយ អំពើអាក្រក់ជាងគេ គឺតាម៉ុកហ្នឹងហើយ ឃើញដាក់ស្ដែងយើងឃើញពី៧៨មក ទៅតាមភូមិភាគយើងមើល...សម្លាប់មនុស្សដល់៧៩ម៉ងហ្នុង ។

ដានី: ពេល៧៩ ពេលដែលយួនចូលមក យើងធ្វើយ៉ាងម៉េចកាលហ្នុង ក្រសួងអឹ អន្តភាពយើងធ្វើម៉េច យើងដកថយ យើងរត់មកខាងនេះយ៉ាងម៉េចទៅ ស្ថានភាពយ៉ាងម៉េចទៅកាលហ្នុង?

ចៀមៈ	កាលហ្នឹងវា៧៩, ៧៨ ខែ១២ ដូចថាវ៉ៃលុកវគ្គទី១, វគ្គទី២អីចឹងទៅណានៅបូព៌ណា ឃើញថាមានបញ្ហាហើយ យើងទប់វាមិនជាប់ដែរ ដល់៧៩ហ្នឹងយើងចេញពីទីក្រុងភ្នំពេញ ខ្ញុំ៧មករា ខ្ញុំនៅវ៉ៃនៅភ្នំពេញតើស ម៉ោង៧, ៨យប់បានដក ។

ដានីៈ	អ៊ីដល់ពេលថ្ងៃ៧ហ្នឹង អ៊ំធ្វើកងទ័ពវិញឬយ៉ាងម៉េច?

ចៀមៈ	ហ្នុងហើយ! ខ្ញុំយប់៦មករា កាលហ្នុងខ្ញុំជូនដំណើរសម្តេចឡើងយន្តហោះទៅបេកាំង យប់ហ្នុងហើយ រៀបចំកាំភ្លើង ឯកងទ័ពហ្នុងអង្គភាពខ្ញុំ...គេហាត់យូហើយ ហាត់របៀបទ័ពណា ។

ដានីៈ	មួយទៀតអ៊ីខ្ញុំចង់ដឹងរឿងទាក់ទងសម្តេច ពីព្រោះខ្ញុំធ្លាប់អានសៀវភៅបរទេសគាត់សរសេរណាយ៉ាន់ ចាន់ដា គាត់និយាយថាសម្តេច កាលពីមុនហ្នឹង ដូចជាមានរត់មកខាងពាយ័ព្យមួយសាហើយ?

ចៀមៈ	ហ្នឹងហើយ! ខ្ញុំនេះអ្នកនាំមក ។

ដានីៈ	អីចឹងអ៊ំអាចជួយជម្រាបខ្ញុំបន្តិចកន្លែងសម្តេចហ្នឹង?

ចៀមៈ	កាលហ្នឹងអង្គការថាឥឡូវនេះយួនចូលស្រុកហើយ ឥឡូវជម្លៀសគាត់ចេញឲ្យមកប៉ោយប៉ែតនេះ ។

ដានីៈ	អាហ្នឹងថ្ងៃណា ឆ្នាំណា?

ចៀមៈ	ថ្ងៃហ្នុងមុនទៅដល់ភ្នំពេញវិញ ដូចថ្ងៃ ២៩ ថ្ងៃ ៣០ ក្នុងចន្លោះហ្នឹងឯង ។

ដានីៈ	ខែធ្នូឆ្នាំ៧៨!

ចៀមៈ	ហ្នុងហើយ! ចេញពីភ្នំពេញម៉ោង ៩យប់ មកដល់ស្វាយម៉ោង ៥ កន្លះ មកបាត់ដំបងកាលហ្នុងកម្លាំងពួកខ្ញុំទាំងអស់ ដូចថានៅកន្លែងកំពង់ឆ្នាំងមានកន្លែងទទួលភ្ញៀវមួយ ដល់ពោធិ៍សាត់មានកន្លែង ទទួលភ្ញៀវមួយ មកដល់បាត់ដំបងមានកន្លែងទទួលភ្ញៀវមួយ កម្លាំងយើងទាំងអស់ ហើមកដល់ស៊ីសុផុននេះ មានកន្លែងទទួលភ្ញៀវមួយ ។

ដានីៈ	ប៉ុន្មាននាក់ដូចថានៅក្នុងឡានហ្នុង?

ចៀមៈ	សម្តេចឪហើអ្នកម្នាង សម្តេចបែន នុត ហើអ្នកម្នាងគាត់ និងអ្នកបម្រើគាត់២នាក់ ៣នាក់ ។

ដានីៈ	ក្នុងឡានមានសម្តេចឪ សម្តេចម៉ែ សម្តេចបែន នុត ហើនិង....

ចៀមៈ	ឡានសម្តេចឪ និងសម្តេចម៉ែ ឡានម៉ាសីុដេសខ្មៅមួយ ហើសម្តេច បែន នុត និងអ្នកម្នាងឡានខ្មៅមួយដែរ ហើឡានអាហ្សីប២ ឡាននាំមុខមួយ ហើឡានបិទពីក្រោយមួយ ៤គ្រឿងរត់មកនៅប៉ោយបែតនេះ គាត់ថាបើយួនបុកមកដល់ហ្នឹងចាំស្តាប់បទបញ្ជារបស់អង្គការ អង្គការថាឲ្យទៅណាទៅហ្នុងទៅ ។

ដានី: កាលហ្នឹងអ៊ីអ្នកនាំមក ឬក៏មាន...

ចៀម: ខ្ញុំអ្នកនាំ ខ្ញុំអ្នកដឹកនាំ ពីព្រោះខ្ញុំធ្លាប់ទទួលសម្តេចតាំងពី៧៣ ការពារផ្ទាល់តាំងពីកន្ទុយនាគ តាំងពីស្រុកសៀមប៉ាំងរហូតដល់នេះ ហើយជូនទៅវិញទៀត ស្គាល់គ្នាតាំងពីនោះមក ៣ឆ្នាំក៏ស្គាល់ ។

ដានី: សម្តេចស្គាល់អ៊ីដែរ?

ចៀម: ស្គាល់! កាលជិតនាំ៣ឆ្នាំ ទៅណាៗតាមខេត្ត ខ្ញុំជូនដំណើរទាំងអស់ ។ ដល់ថ្ងៃហ្នឹងគាត់ឲ្យជូនដំណើរសម្តេចមកស្វាយ គាត់ថាបើមានអាសន្នម៉េច គាត់បញ្ជាថាឲ្យគាត់ចូលថៃក៏ចូលដែរ ។

ដានី: ដែលអ៊ីនាំសម្តេចឪ យានមកហ្នឹង អ៊ឹអៀង សារី គាត់ប្រាប់ អ្នកបញ្ជាអ៊ីផ្ទាល់ម៉ង?

ចៀម: បាទ! ចាំនៅហ្នឹង ដល់ថ្ងៃ៤គាត់ហៅទៅភ្នំពេញវិញ ។

ដានី: អ៊ឹអៀង សារី ហៅទៅភ្នំពេញវិញ ឬក៏អ៊ី...?

ចៀម: បាទ! អ៊ឹអៀង សារី គាត់ហៅ ប៉ុនអង្គការចាត់ឲ្យគាត់ហៅណា បានប្រជុំនៅកន្លែងផ្ទះលេខ១កន្លែងជិតវត្តភ្នំ កន្លែងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារាល់ថ្ងៃនេះ ធ្វើការ... ជប់លៀងអីហើយ ដូចថាឥឡូវយួនចូលស្រុកហើយឲ្យសម្តេចឪយានទៅប៉េកាំង ទៅអង្គការសហប្រជាជាតិ ដើម្បីស្រែក ពីព្រោះយួនវាចូលហើយណា គាត់ឡើងយប់ថ្ងៃ៦មករា ម៉ោង៨យប់ហើយបានឡើងតើស ខ្ញុំជូនដំណើរគាត់មកហើយ គាត់ឡើងទៅបានខ្ញុំទៅបើកអាវុធយប់ហ្នឹងឯកម្ចាំងខ្ញុំ ។

ដានី: អ៊ីចឹងថ្ងៃ៤ អ៊ីជូនគាត់ពីស្វាយត្រឡប់ចូលភ្នំពេញវិញ?

ចៀម: បាទ! ចូលភ្នំពេញវិញ ។

ដានី: អ៊ីចឹងមកដល់ភ្នំពេញថ្ងៃ៤ ដដែល ឬក៏យ៉ាងម៉េច?

ចៀម: អត់ទេ! ថ្ងៃ៤ធ្វើដំណើរ ថ្ងៃ៥ ធ្វើដំណើរយឺតៗហ្នឹង ដល់ល្ងាចថ្ងៃ៥ ជិតម៉ោង៤ ម៉ោង៥ ហើយបានមកដល់ភ្នំពេញ ដល់ដំណាក់គាត់នៅជិតវិមានឯករាជ្យ ដំណាក់ថ្មីណា ។

ដានី: មិនមែននៅក្នុងវាំងទៀតទេ?

ចៀម: អត់នៅវាំងទេ! គាត់ចេញហើយវាំងកាលហ្នឹង ធ្វើកូនវាំងតូចមួយ ខ្ញុំអ្នករៀបចំ អ្នកធ្វើ ។

ដានី: កន្លែងជិតផ្ទះសម្តេចហ៊ុនសែន រាល់ថ្ងៃហ្នឹង?

ចៀម: ហ្នឹងហើយ!

ដានី: កន្លែងស្ពានទូតកូរ៉េខាងជើង!

ចៀម: ហ្នឹងហើយ ។

ដានី៖ អីចឹងសម្ដេចចេញពីវាំងតាំងពីអង្គាល?

ចៀម៖ វាំងហ្នឹងពាក់កណ្ដាល ដើម៧៨ហើយបានធ្វើ គាត់ថាកន្លែងទុកអង្គការទទួលភ្ញៀវទៅកន្លែងហ្នឹង គាត់ដកខ្លួនមកនៅខាងក្រៅ ។

ដានី៖ ដល់ថ្ងៃ៥ ហ្នឹងប្រជុំ...

ចៀម៖ ប្រជុំហើយ ជប់លៀង ។

ដានី៖ ជប់លៀងជាមួយសម្ដេចអីហ្នឹងដែរ?

ចៀម៖ បាទ! មានណួន ជា មានប៉ុល ពត មាន សុន សេន មានអៀង សារី...

ដានី៖ ជប់លៀងនៅកន្លែងស៊ី ឌី ស៊ី ហ្នឹង?

ចៀម៖ បាទ! កាលហ្នឹងគេហៅថាផ្ទះលេខ១ ។

ដានី៖ អ៊ំចូលរួមជប់លៀងហ្នឹងដែរ?

ចៀម៖ អត់ទេ! ខ្ញុំអត់ចូលជប់លៀងទេ នៅការពារខាងក្រៅ ។

ដានី៖ ដល់ជប់លៀងហើយ ថ្ងៃ៦បាន...

ចៀម៖ ថ្ងៃ៥ធ្វើការហើយជប់លៀង ដល់ថ្ងៃ៦ធ្វើការទៀត ដល់យប់បានជូនដំណើរទៅឡើងយន្តហោះទៅប៉េកាំង ។

ដានី៖ កាលឡើងកប៉ាល់ហោះទៅបេកាំងម៉ោងប៉ុន្មាន?

ចៀម៖ ម៉ោងជិត៨ហើយ ។

ដានី៖ ម៉ោង៨យប់?

ចៀម៖ បាទ!

ដានី៖ ពីណាខ្លះដែលឡើងយន្តហោះទៅជាមួយសម្ដេច?

ចៀម៖ ទេ! មានតែសម្ដេចបែន នុន គាត់ ហ៊ីក្រុមអ្នកបម្រើគាត់២,៣នាក់តែប៉ុណ្ណឹងឯង ។

ដានី៖ អ៊ំអៀង សារី មានទៅជាមួយគាត់ទេ?

ចៀម៖ អត់ទេ!

ដានី៖ ឡើងទៅហ្នឹងអ៊ំដឹងថាគាត់យាងទៅណា?

ចៀម៖ ទៅប៉េកាំង បានទៅ ថាទៅ អង្គការសហប្រជាជាតិ ដល់យួនចូលភ្នាមអីចឹង មានអីចឹងឯណា សម្ដេចនឹកបណ្ដោយ ដេយើងបណ្ដោយ ។

ដានី៖ ទៅដល់បានដេរ?

ចៀមៈ ទៅដល់ប៉ែកាំងហ្នុងដេយើងបណ្ដោយ គាត់ចោទប្រកាន់យើង គាត់ខឹងយើង គាត់មិនបានទៅអន្ដការសហប្រជាជាតិឯណា...។

ដានីៈ ដល់អីចឹង ចាប់ពីពេលហ្នឹងទៅអឹចាប់ផ្ដើមបំពាក់អាវុធ បំពាក់អីវ៉ែជាមួយយួនវិញទៅ?

ចៀមៈ បាទ! យប់ហ្នុងខ្ញុំបើកអាវុធទល់ភ្លឺ ចាប់ពីម៉ោង ១១ជាង ជិតម៉ោង១២ បានពុស្ដុះអាវុធនៅទីក្រុងភ្នំពេញ ដុះហ្នុងគឺថាមកតាមកប៉ាល់ទឹកផង មកតាមផ្លូវជាតិលេខមួយផង ហើយពុតែបាញ់អាដូសេត អាអីនោះ ខ្ញុំនៅព្រឹកនោះខ្ញុំរៀបចម ខ្ញុំជួបតាម៉ុកទៀត ជួបតាម៉ុកប្រហែលម៉ោង៨ព្រឹក គាត់ថាឲ្យឡើងមក ខ្ញុំថាកម្លាំងយើងមាន កាលហ្នុងគាត់ឲ្យខ្ញុំទៅទប់នៅអ្នកលឿងទៅ យកកម្លាំងទាំងអស់ទៅទប់នៅអ្នកលឿងទៅ ចាំគាត់ឲ្យរថក្រោះ២០គ្រឿងទៅ បេះតែចាំៗ ចាំអារថក្រោះ បេះតែចាំបទបញ្ជា កាលហ្នុង បងម៉េត គាត់អ្នកដឹកនាំបញ្ជានៅកន្លែងអគ្គសេនាធិការហ្នុង បងម៉េតក៏បាត់ស្ងាត់ប្រៀប ។

ដានីៈ ពីណាគេ?

ចៀមៈ បង ម៉េត ។

ដានីៈ អូ! ស៊ូ ម៉េត!

ចៀមៈ បាទ! គាត់បញ្ជាការ បាត់អត់មានបញ្ជាអី បាត់ម៉ង ដល់ពុកាំភ្លើង ប្រចូកប្រចល់នៅភ្នំពេញហ្នឹង ពួកខ្ញុំ ខ្ញុំឲ្យត្រៀមចាប់ពីវ៉ារទេះភ្លើង ត្រៀមរហូត ដល់ផ្ទះចេង ហេង ពេទ្យលោកសង្ឃចាក់ទៅស្ទឹងមានជ័យនោះណា ប្រហែលម៉ោង១២ជាង យួន មកដល់ទីក្រុងភ្នំពេញមកដល់ផ្សារថ្មី ខ្ញុំឲ្យកម្លាំងទៅស៊ើប យួនមកដល់ យួនច្រើន ។

ដានីៈ កាលនោះអ្នកនៅក្រសួងការបរទេសរៀបជាកងទ័ព?

ចៀមៈ បាទ! រៀបជាកងទ័ពទាំងអស់ សុទ្ធតែប្រុសៗ ហីស្រីមួយចំនួន ។

ដានីៈ បានជាកងពល?

ចៀមៈ បានមួយវរៈសេនាធំ ។

ដានីៈ អីចឹងយ៉ាងទៅអឹ ដល់ពេលយួនចូលមកហើយ យើងទប់ទល់អត់ឈ្នះយើងដកយ៉ាងម៉េចទៅ?

ចៀមៈ អត់ឈ្នះ យើងដកមកនៅភ្នំស្នាតពង បានមករៀបចំកងទ័ពនៅហ្នុង២ខែកន្លះ ពាក់កណ្ដាលខែ៣បានខ្ញុំដកចេញពីហ្នុង ដកមកនៅពាយ័ព្យ... វ៉ៃរហូត វ៉ៃនៅបាត់ដឹង ស្លាប់ច្រើនណាស់វាដាក់យើងមកក៏ស្លាប់ យើងដាក់ទៅវាវិញក៏ស្លាប់ដែរ ចុះអាវុធ និងអាវុធ ។

ដានីៈ កាលហ្នុងចុះយើងមានអាវុធគ្រប់គ្រាន់ដែរ?

ចៀមៈ មិនមានគ្រប់គ្រាន់ទេ កងទ័ពស្រួចមិននៅព្រំដែន ដល់វាវ៉ៃឆ្លាយព្រំដែនខាងក្នុងវលុងមានស្អី មានតែរបេះរបោះធម្មតាហ្នុង គ្មានទេទើបរៀបចំក្រោយហ្នុង ចុះបើតាំងពីណានោះចេះតែ បុកៗ កងទ័ពក្រាសតាមព្រំដែន របើកអាព្រំដែនហ្នុងមានស្អី បាក់ទីណាត់ទីណែង...

ដានីៈ អ៊ីចឹងចេះតែដកថយរហូតមក?

ចៀមៈ ពីភ្នំពេញមករហូតដល់ខែ៤ បានមកដល់ព្រំដែន មកដល់ប៉ៃលិន។

ដានីៈ តាៗគាត់មកជាមួយដែរ ឬយ៉ាងម៉េច?

ចៀមៈ អត់ទេ! កាលយួនចូលភ្នំពេញខ្ញុំអត់បាននៅជាមួយតាៗគាត់ អ៊ំអៀង សារី គាត់មកមុន មកជាមួយគ្រួសារគាត់ មកនៅជាប់ជាមួយទូតចិន ទូតចិនទើបទៅតើស។

ដានីៈ ទូតចិនអត់ទាន់ទៅអ៊ីចឹង?

ចៀមៈ ទូតចិននៅជាប់ជាមួយតាៗហ្នឹង ខ្ញុំខែ៤បានមកដល់ប៉ៃលិន ខែ៥ បានមកជួប អ៊ំអៀង សារី បានមកជួប តាប៉ុល ពត នៅសំឡូតនេះ។

ដានីៈ អ៊ីចឹងពេលអ៊ំតស៊ូ ពេលវ៉ៃហ្នឹងអ៊ំទាក់ទងតាៗជាប់ដែរ ឬអត់ទេ?

ចៀមៈ ទាកងទង! វាមានទូរលេខទាក់ទងគ្នាបាន យើងបានដំណឹងជូនទៅគាត់ គាត់ណែនាំទៅកាល ហ្នុងណា។

ដានីៈ ដល់ខែ៤មកដល់ប៉ៃលិន អ៊ីចឹងពេលមកដល់ប៉ៃលិនយើងរៀបចំកងទ័ពយ៉ាងម៉េចទៅ?

ចៀមៈ ខ្ញុំមកដល់ប៉ៃលិន កម្លាំងចូលពីត្រាត ថៃដឹកមកដាក់នៅខ្លែម រត់មកពីសៀមរាបពីខាងជើងមក ជុំខាងណុះ មុនស្សរាប់សែន អូ!វេទនាមែនទែន។

ដានីៈ មនុស្សរាប់សែនហ្នុង សុទ្ធតែកម្មាភិបាល យុទ្ធជន ឬក៏មានប្រជាជនមកជាមួយដែរ?

ចៀមៈ មកទាំងអស់ គឺថាភាគច្រើនទី១កងទ័ព ប្រពន្ធកងទ័ព ម៉ែឪកងទ័ពនោះណា បងប្អូនកងទ័ព នោះណា ទី២ក្រសួងមន្ទីរ គ្រប់ក្រសួងមន្ទីរទាំងមូលទាំងអស់ ហីក្រសួងហ្នុងរៀបចំទៅជា កងទ័ពទាំងអស់ ឲ្យតែយុវជន យុវនារី រៀបចំជាកងទ័ពទាំងអស់ យុវជនគឺប្រយុទ្ធនៅខាង មុខ ហីនារីគឺកងដឹកជញ្ជូន រៀបចំទាំងអស់ ចំណែកកូនចៅ ចាស់ៗអីនៅខាងក្រោយទៅ យាយៗចាស់ណា រៀបចំទៅ ហើយចេះតែវ៉ៃទៅ។

ដានីៈ អ៊ំគិតរៀបចំខ្លួនឯង ឬក៏មានការណែនាំពីអ៊ំៗ តាៗខាងលើ?

ចៀមៈ ណែនាំពីខាងលើណា ខាងលើគាំទ្របានយើងធ្វើកើត ខាងលើដោះស្រាយទាំងអស់ ទាំង នយោបាយ ទាំងយោធា ទាំងសេដ្ឋកិច្ច ទាំងបច្ចេកទេសអីដោះស្រាយទាំងអស់។

ដានី: ចុះអ៊ឹ ដូចថាតាៗគាត់មានការប្រែប្រួលអីយ៉ាងម៉េចដែរ ដូចថាកាលជំនាន់៣ឆ្នាំគាត់នៅហ្នឹង គាត់គ្រប់គ្រងអីចុងណា ពេលយើងរត់ដល់ប៉ៃលិនយើងរៀបចំដូចអឹមានប្រសាសន៍មិញណា មានកងដឹកជញ្ជូន មានកងទ័ពវៃអីចឹងណា ចុះកាលហ្នឹងយើងរៀបចំគោលនយោបាយអីយ៉ាងម៉េច ខុសពីមុនអីយ៉ាង ម៉េចខ្លះទៅ?

ចៀម: ខុសគ្នាបន្តិចដែរ ខ្ញុំឃើញថាតស៊ូសំងាត់មួយបែប កាលឆ្នងកាត់សង្គ្រាម៥ឆ្នាំមួយបែប ដល់ជំនាន់៣ឆ្នាំមួយបែបដែរ ដល់៧៩មួយបែបទៀត ។

ដានី: បាទ! យ៉ាងម៉េចខ្លះទៅអ៊ី ដូចថាតស៊ូបែបហ្នឹង?

ចៀម: យើងតស៊ូសម្ងាត់ វារបៀបសម្ងាត់ ហីមុនស្សវាតិច ប៉ុនដល់រដ្ឋប្រហា ១៨មីនា ឆ្នាំ១៩៧០នេះ សង្គ្រាម៥ឆ្នាំ ចាប់ពីហ្នឹងមកយើងមានកងទ័ព យើងកងស្នែងកងដឹកជញ្ជូន គេហៅកងស្នែង ដាក់សមរភូមិណាដាក់មួយខ្សែ ដូចថាធ្វើសង្គ្រាមកាលនេះដូចថាធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ដូចថាមនុស្សវាចូលចិត្តធ្វើ ស្ម័គ្រចិត្តធ្វើតែម្តង ដើម្បីរំដោះជាតិវាម្យ៉ាងដែរ ធ្វើបដិវត្តហ្នឹងគេហៅថាធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យធ្វើនោះចប់ ១៧ មេសា ឆ្នាំ៧៥ ចប់អាហ្នឹង គឺស្ងាត់តែម្តងអត់មានអីទេ ដល់៣ឆ្នាំទៀតឃើញថា ៧៦, ៧៧ នៅឆ្នាំ៧៦ ក៏អត់សូវអីប៉ុន្មានដែរ ដល់៧៧នោះ គឺមានហៅថាចលនាចង់រំលំរបបហ្នឹង ។

ដានី: ដូចថាវាមានខ្សែមួយនៅក្នុងហ្នឹងដូចថាក្បត់ចង់រំលំបដិវត្តន៍!

ចៀម: ហ្នឹងហើយ! ចង់រំលំបដិវត្ត ហីក្នុងហ្នឹងវាចោទជាបញ្ហាខ្លាំងជាងគេ គឺវាចោទបញ្ហានិរតី ហើយវាចោទភូមិភាគបូព៌ានេះ វាចាប់ និរតីវាចោទ និរតីមុនស្សវាច្រើន វាស្រេចឃ្លាន់អំណាច ហីខាងមជ្ឈឹមចេះតែលើកដំកើងតាម៉ុក ចេះតែលើកដំកើងៗ ធ្វើទៅវាខុស បានអីចឹង ដល់យួនបុកមក ខាងបូព៌ាហ្នឹងគេចោទថាក្បត់ មកពីក្បត់ហ្នឹងហើយបានជាយួនចូលបាន បើមិនក្បត់យួនចូលមិនបានទេ ទៅជារឿងអីចឹងទៅណា... ដល់ក្រោយផ្លាស់ប្តូរយោធាផងផ្លាស់ប្តូររដ្ឋាបាលផង យកកម្លាំងពីខាងនិរតីទៅគ្រប់គ្រងគ្រប់ភូមិភាគ អាផ្ទៃក្នុងឯងក៏ច្របូកច្របូលស្អីក៏ចោទប្រកាន់គ្រាន់តែជំឡូងមួយមើម បាក់ស្លាបព្រាមួយ ក៏ចោទប្រកាន់ ថាស្អីក៏ចោទប្រកាន់ទាំងអស់ វាទៅជាជុំវិញខ្លួនឯងវាទៅជាខ្លាំងណា អត់ដូចកាលជំនាន់តស៊ូ៥ឆ្នាំ យើងប្រមូលផ្តុំសាមគ្គីគ្នាល្អណាស់ ដល់ពេលនេះទៅជារបៀបដណ្តើមនិន្នាគ្នា របៀបដណ្តើមអំណាច ឃើញវាលេចធ្លោ អ្នកមិនដែលគ្រប់គ្រង ដូចជាវាអាម៉េចទេ មើលទៅដូចចង់ស៊ីសាច់ហុចឈាមគ្នាអាម៉េចទេ ឃើញអីចឹង ។

ដានី៖ ប៉ុន្តែអ៊ំរឿងហ្នឹងតាំងពីជំនាន់ពតឆ្នាំ ឬ ទើបដឹងក្រោយទេ ដូចថាដកដំឡូងមួយមើមបាក់ស្លាប ព្រាមួយ បាក់នង្គ័លអីក៏ត្រូវចោទប្រកាន់នោះអ៊ំដឹងតាំពីជំនាន់ពតឆ្នាំ ឬក៏យ៉ាំងម៉េច?

ចៀម៖ ដឹងតាំពីជំនាន់ពតឆ្នាំ ពីព្រោះខ្ញុំដើរគ្រប់ភូមិភាគ។

ដានី៖ ចុះអ៊ំៗ តាៗ គាត់ដឹងរឿងហ្នឹងដែរទេ?

ចៀម៖ ដឹង! គាត់ដឹងដែរ គាត់និយាយថា.. សហករណ៍ជឿនលឿន សហករណ៍ជឿនលឿនហ្នុង ហើយ គឺឃើញថាប្រជាជនខ្លះហូបបបរលាយជាមួយត្រកួន ខ្ញុំឃើញជាក់ស្តែងនៅពាយ័ព្យ ហ្នុងដែរ នៅក្នុងស្រុកនេះ នៅផ្លូវទៅពោធិ៍សាត់ ខ្ញុំឃើញ...។

ដានី៖ ឃើញសហករណ៍ជឿនលឿនហ្នុងហូបបបរ?

ចៀម៖ ហ្នឹងហើយ!

ដានី៖ ចុះស្ថានភាពប្រជាជនយ៉ាំងម៉េច ពេលអ៊ំឃើញកាលហ្នុង?

ចៀម៖ ឃើញប្រជាជនធ្វើទំនប់ ធ្វើប្រឡាយនោះណា... កាលនោះខ្ញុំនិយាយលេងជាមួយតាញឹមថា បើយកតាមឯកសារណា បើកន្លែងណាប្រជាជនហូបបបរ បានថាកម្មាភិបាលនោះ អត់កើត ជាការទេកម្មាភិបាលនោះ ខុសពីឯកសារ ខ្ញុំនិយាយលេងផង និយាយមែនផង។

ដានី៖ អូ! និយាយជាមួយតាញឹមផ្ទាល់?

ចៀម៖ បាទ! ខ្ញុំនិយាយតើស ខ្ញុំនិយាយជាមួយតាញឹម ខ្ញុំនិយាយលេងផង មែនផង បើតាម ឯកសាររបស់បក្ស អត់កើតកទេ ម្នាភិបាលនោះអត់កើតជាការអីទេ។

ដានី៖ ឆ្នាំណាដែលអ៊ំទៅឃើញនោះ?

ចៀម៖ នែ! ៧៨។

ដានី៖ ឆ្នាំ៧៨ តាញឹមគាត់នៅទេ!

ចៀម៖ ដើមឆ្នាំ ៧៨!

ដានី៖ កាលហ្នុងអ៊ំទៅជាមួយពីណាគេ?

ចៀម៖ កាលហ្នុងទៅជាមួយតាប៉ុល ពត កាលហ្នុងអត់មកតាមផ្លូវជាតិលេខ៥ទេចេញទៅសៀមរាប ចេញទៅកំពង់ចាមណា ជិះកប៉ាល់ចុះទៅភ្នំពេញ កាលមកវិញ។

ដានី៖ តានួន ជា គាត់ទៅជាមួយដែរ?

ចៀម៖ អត់ទេ! ទៅជាមួយតាប៉ុល ពតទេ។

ដានី៖ អ៊ំ អៀង សារី ក៏អត់បានទៅដែរ?

ចៀម៖ អត់ទេ! អ៊ំអៀង សារី គាត់អត់បានទៅទេ គាត់នៅក្រសួង។

ដានីៈ ចុះអ៊ីដល់មកនៅក្រសួងការបរទេសហើយ ក៏នៅតែទៅជាមួយតាៗ?

ចៀមៈ ទៅតើ! បើថាគាត់ត្រូវការគាត់ហៅពេលណាទៅពេលហ្នឹង អ៊ំអៀង សារី គាត់ចាត់តាំង ហើយខ្ញុំទៅ អត់ចេះថាអីទេ តែទៅ ទៅហើយ ។

ដានីៈ អីចឹងអ៊ំៗខាងលើគាត់ដឹងដែរទ! ដូចថា តាប៉ុល ពត តា នួន ជា គាត់ទៅឃើញ...

ចៀមៈ ទៅឃើញ ដឹងតើស អីចឹងបានថាចុងឆ្នាំ៧៨ មិនទមានឯកសារមួយ គេហៅថាអនុគ្រោះណា ដូចថាភាពអនុគ្រោះ កុំឲ្យចេះតែចោទប្រកែប្រកាន់ ជុំវិញខ្លួនឯងឲ្យទៅជាខ្មាំងនោះណា ។

ដានីៈ បាទ! ខ្ញុំដឹងដែរថាមានឯកសារមួយនៅឆ្នាំ៧៨ ថាយើងអនុគ្រោះ យើងលើកលែង ។

ចៀមៈ បាទ! យើងអនុគ្រោះ លើកលែង មានអីចឹង ។

ដានីៈ អាហ្នឹងចេញពីខាងលើដឹងដែរ?

ចៀមៈ បាទ! ខាងលើដឹងដែរ ដល់អស់កម្មាភិបាលសំខាន់ៗ ជាកម្មាភិបាលមជ្ឈិម ទៅនៅតាមភូមិភាគបើគិតទៅស្គាល់គ្នាទាំងអស់ ហើតំបន់មួយចំនួនក៏ស្គាល់គ្នាទាំងអស់ដែរ ហើស្រុកមួយចំនួនក៏ស្គាល់ដែរ ចុះបើយើងនៅកណ្តាល ខាងណាមកយើងដឹងទាំងអស់ ហើយយើងនៅកណ្តាលអ្នកណាៗក៏គេគោរពយើងដែរ ហើយើងក៏មានមនោសញ្ចេតនា ស្មោះណាស់ អារឿងជនជាតិស្មោះណាស់ ទាក់ទងដោយស្មោះត្រង់នឹងគ្នាហ្នុងឯង ។

ដានីៈ តាញឹមអីអ៊ំស្គាល់គាត់ ហ៊ាននិយាយជាមួយគាត់!

ចៀមៈ បាទ! ខ្ញុំហ៊ាននិយាយលេងគ្រប់ភូមិភាគ ពួកមជ្ឈិមៗអីខ្ញុំនិយាយ ។

ដានីៈ មួយទៀតខ្ញុំធ្លាប់បានអានឯកសារដូចខាងតេឡេក្រាមទាក់ទងជនជាតិចាមនៅខាងឧត្តរ ហី ខាងបូព៌ាអីណា កាលជំនាន់ហ្នុងជំនាន់កោះផល កំពង់ចាមអី អ៊ំមានដឹងរឿងហ្នឹងដែរអត់ ដូចថាកាលហ្នុងមានចាមប៉ះបោរអីមានសម្លាប់កម្មាភិបាល ហើយដូចថាជម្លៀស ជនជាតិចាមចេញពីតំបន់ហ្នុងអី ?

ចៀមៈ ខ្ញុំដឹងមិនអស់ទេ អារឿងហ្នុង ប៉ុនព្ត គាត់និយាយថាមានចលនា និយាយរួមចលនាប្រឆាំងបដិវត្តន៍វាមានខ្លះៗអីចឹងណា គេលើកពិសោធន៍រៀនសូត្រ គេហៅជាកន្លែង ជាចំនុចតូច វាមានអីចឹងដូច្នេះត្រូវប្រយ័ត្ន វាមានអីចឹង ប៉ុនដល់៣ឆ្នាំមានចោទប្រកាន់មុនដំបូងសេអ៊ីអា ហើយបានគេហៅកាហ្សេបេ ហើយដល់ក្រោយមកទៀតកុកមិញតាំង វាមានខ្សែ៣នៅកម្ពុជា ដែលចង់រំលំនៅកម្ពុជា មានខ្សែ៣ហ្នឹង ខ្សែ៣នេះគេសាមគ្គីគ្នា គេរំលំយើង ហើយត្រូវប្រយ័ត្នបន្តិច ខ្មាំងរបស់បដិវត្តន៍ ។

ដានីៈ មាន សេអ៊ីអា កាហ្សេបេ និងកុកមិញតាំង!

ចៀមៈ ហ្នឹងហើយ ។

ដានីៈ ចុះខ្មែរខាងយួនវិញ?

ចៀមៈ យួនគេអត់និយាយទេ គេនិយាយចំថា យួនមហ្មិតាវាគឺហៅសហពន្ធឥណ្ឌូចិន ហីយើង១៧ មេសានោះយើងឈ្នះមុនយួន យួនអត់សប្បាយចិត្តទេ ហី៧៣នេះយួនបបួលយើងចចារ តែយើងអត់ ចចារ ។

ដានីៈ ចចាររឿងអី?

ចៀមៈ ចុះគេវៃជាមួយខាងត្បូង គេមិនចចារជាមួយអាមេរិក ហើយគេអូសយើងឲ្យចចារជាមួយ អាមេរិកដែរ ៧៣ខែ៦, ខែ៧ សភាពការណ៍អត់ល្អយើងអត់ចចារទេ យើងថាអត់មាន គ្រាប់ក៏យើងវៃដែរ ពាក្យស្លោករបស់យើងថា យកគ្រាប់ពីខ្មាំងវៃខ្មាំងវិញ ហីយើងយក សង្រ្គាមឈ្លប... មានប្រជាជនគឺមានទ័ព មានប្រជាជនគឺមានសេដ្ឋកិច្ច មានប្រជាជនគឺចង់ ស្មើអីក៏កើតដែរ ។

ដានីៈ ហីដល់ក្រោយមកដល់ដំណាក់កាល៧៩ យើងអាម៉េចទៅវិញ?

ចៀមៈ ៧៩! យើងត្រូវរំលាយបក្សកុម្មុនីស្តកម្ពុជាហើយយើងត្រូវប្រមូលកម្លាំង ។

ដានីៈ ម៉េចក្រោយ៧៩ ខុសពីជំនាន់ពតឆ្នាំម៉េចវិញ?

ចៀមៈ កាលសង្រ្គាម៥ឆ្នាំ ខ្លួនពីពីងខ្លួនឯងទៅរួច ដល់៧៩ បើនិយាយពីចលនាហៅថា វៃហើយឲ្យ មានកម្លាំងវៃឲ្យឈ្នះវាមានការលំបាក ប៉ុនវាល្អគ្រន់នេះ... បើនិយាយពីរឿងជំនួយអត់ ចោទទេ បើនិយាយពីកាំភ្លើងគ្រាប់រំសេវអត់ចោទ បើនិយាយពីហូបចុកអត់ចោទ ទេហូប ទំនើបទៀត ដូចថាយើងហូបមានសាច់គោ មានស្ករ មានអង្ករ មានប៊ីចេង មានប្រហុកផ្អក មានសាច់កំប៉ុង មានត្រីខ មានខ្លាញ់ មានសព្វគ្រប់ទាំងអស់ណា អាហ្នឹងហៅថាការឧបត្ថម្ភ ប៉ុនថាបើចលនាជាក់ស្តែងសង្រ្គាមប្រជាជន សង្រ្គាមឈ្លបវាអត់ចោទទេ វាយូអង្វែងបាន អត់ចោទទេ មួយវគ្គហ្នុងយើងការពារខ្លួន តស៊ូប៉ុន្មានឆ្នាំទៀតក៏អត់អីដែរ ប៉ុន្តែប៉ុន្មានឆ្នាំចុង ក្រោយនេះវាច្របូកច្របល់ដូចថាយើងមិនចូលរួមក្នុងកិច្ចព្រមព្រៀងបារី បានធ្វើកិច្ចព្រម ព្រៀងបារី ដល់បោះឆ្នោតយើងទៅ ចង្រៃតាម៉ុកហ្នឹង គាត់ថាឥឡូវ អនុវត្តខទី១ ទី២ មិនបានមិនបាច់ទៅចូលរួមបោះឆ្នោតជាមួយទេ ឥឡូវបន្តវៃទៀតទៅ ហីទាំងអស់គ្នាហ្នុង ប្រជុំនៅភ្នំឆ័ត្រស្តាប់តាម៉ុក ហ្នុងទៀតហើយ ។

ដានីៈ ប្រជុំភ្នំឆ័ត្រស្តាប់តាម៉ុកម៉េច?

ចៀមៈ តាប៉ុល ពត ស្ដាប់តាម៉ុក ថាបើវ៉ៃទៀតក៏វ៉ៃទៅ ដូចថាគាត់ដូចលែងម្ចាស់ការ កាលសង្គ្រាមប្រជាជាតិផ្សេង ដល់៣ឆ្នាំវាផ្សេង ដល់មកយួននេះវាខ្សោយការគិតគូរ ខ្សោយស្មារតី វារាងភាំងដែរ ហីស្អីៗបណ្ដោយតាមតាម៉ុក ដល់ចុងក្រោយមានរឿងផ្ទៃក្នុង គឺតាម៉ុក ចង់ចាប់តាអៀង សារី ចង់ធ្វើរបៀប ៣ឆ្នាំទៀតណា ដល់អីចឹងកម្លាំងប៉ៃលិន កម្លាំងម៉ាឡៃ អ៊ំអៀង សារី គាត់គ្រប់គ្រងផ្ទាល់បែកមុខសញ្ញាគ្នា ឥឡូវអត់អាចតាប៉ុល ពត មកចុះដោះស្រាយទេ តាម៉ុក មកដោះស្រាយ មកដោះស្រាយនៅម៉ាឡៃនេះ ដូចយកសាំងមកចាក់លើភ្លើងឲ្យក្ដៅទៀត ខាងខ្ញុំមុនដំបូងអត់ចង់នៅក្រោមការគ្រប់គ្រងរបស់សុន សេនទេ។ សុន សេន មានគម្រោងចង់ចាប់មេដឹកនាំទាំងអស់ដូចបងសុក ភាព អ៊ី ឈាន អីចឹងទៅឃើញថាវាប្របូលប្របល់ ក្នុងដឹកនាំវាលែងឯកភាពគ្នា បែកបាក់គ្នាហើយ ដល់ថ្ងៃមួយនោះវិទ្យុ...ប្រកាស់ថា អៀង សារី ក្បត់ សុខ ភាព ក្បត់ អ៊ី ឈាន ក្បត់ ដល់ប្រកាសអីចឹង ពួកខ្ញុំពីរកន្លែងហ្នឹងប៉ះបោរឡើង ឥឡូវគេចោទថាយើងក្បត់ ឥឡូវទាក់ទងទៅរដ្ឋាភិបាលហ៊ុន សែន ទៅ ផ្ដាច់ខ្លួនទៅខ្ជិលតស៊ូទៀតក៏គ្មានន័យដែរ គ្នាប៉ុណ្ណឹងបែកបាក់គ្នាទៀត ឃើញថាវាអត់ទៅរួច ក៏ផ្ដាច់ខ្លួនទៅ កងពលកណ្ដាលហ្នុងពណា ៣២០ កងពលតាបិតនោះមួយទៀត កងពល៧០៥ អាគេនៅកណ្ដាល គេនៅក្រោមបញ្ជារបស់សុន សេន តាម៉ុកបញ្ជាឲ្យអាពួកហ្នឹងមកវ៉ៃខ្ញុំនៅម៉ាឡៃ ហើបញ្ជាឲ្យវ៉ៃប៉ៃលិន ចុះគេនៅកន្លែងគេនៅជាមួយគ្នាគេអត់វ៉ៃ គេសុខចិត្តចចារ គេមកចចារ គេសួរថាយើងនៅជាមួយគ្នា ម៉េចបានយើងផ្ដាច់ខ្លួនទៅចូលជាមួយរដ្ឋាភិបាល យើងថាខុសត្រូវផ្ទៃក្នុងយើងមាន ហេតុអីវិទ្យុទៅប្រកាសថាគេក្បត់ ឥឡូវក្បត់គេទៅហើយ គេខ្ជិលមកវិញ គេសុខចិត្តចូលជាមួយរដ្ឋាភិបាល រឿងវាអីចឹងតើស អាហ្នឹងសភាពការណ៍វាអីចឹង ចៃដន្យពួកខ្ញុំមានរថក្រោះ២គ្រឿង ខាងប៉ៃលិននោះមានរថក្រោះច្រើន ៧, ៨ គ្រឿង ប៉ៃលិនគេវ៉ៃពីហ្នុងមក បើថាគេចូលជាមួយក៏មក បើគេមិនចូល... បានតាម៉ុក ចេញពីកន្លែងកណ្ដាលនេះមកបញ្ជា បងនី កន អីនេះ ក៏រត់ចេញពីនេះ ទៅសំងំនៅសំឡូត ហីពួកខ្ញុំផ្សារភ្ជាប់... ដល់មេៗបណ្ដេញគ្នាទៅអស់ហើយ ភ្ជាប់គ្នា យើងមិនវ៉ៃគ្នាទេ យើងចូលរដ្ឋាភិបាលទៅ។

ដានីៈ ចូលខាងរដ្ឋាភិបាល ខាងប៉ៃលិន ហីខាងម៉ាឡៃយើងហ្នឹង?

ចៀមៈ បាទ! បើគ្មាន ម៉ាឡៃ ប៉ៃលិននោះ ក៏គ្មានថ្ងៃនេះទេ កុំប្រឡំនោះ បើថាផ្ទៃក្នុងមិនងើបមិនងាយទេ សង្គ្រាមឈ្លបមិនងាយទេ ដូចខ្ញុំថាអីចឹងម៉េច។

ដានី៖ ចុះ សុន សេន មានបញ្ហាអី បានគេសម្លាប់គាត់?

ចៀម៖ រឿងផ្ទៃក្នុងខាងលើ សុន សេន គ្រប់គ្រងកន្លែងនេះ គ្រប់គ្រងម៉ាខ្សែអត់បាន គ្រប់គ្រងប៉ៃលិនអត់បាន ខាងលើចោទប្រកាន់ថា សុន សេន ហ្នឹងអត់បានការអីទេ តាម៉ុក ហ្នឹងហើយសម្លាប់ សុន សេន កាលនោះវាមានបញ្ហាផ្ទៃក្នុង ប៉ុល ពត គេអត់ឲ្យធ្វើការទេ ឲ្យនៅមួយកន្លែង... ចុះពីខាងលើចុះមកខាងក្រោមបំផុសមហាជននោះ ទៅជាចំណាប់អារម្មណ៍ ប៉ុល ពត អីចឹងរឿងផ្ទៃក្នុងចាប់ ប៉ុល ពត ធ្វើជាចំណាប់ខ្មាំងវិញ ផ្ទៃក្នុងស្មុគស្មាញមែនទែន ចុងក្រោយហ្នុង តាម៉ុក ចាត់វិធានការណ៍សម្លាប់ ប៉ុល ពត ទៀត រឿងវាអីចឹង ស្មានថាសម្លាប់ប៉ុល ពត បានហើយ គាត់គ្រប់គ្រងប្រទេសបាន តាម៉ុក អត់កើតការទេ មុនស្សហ្នឹង មនុស្សវាអាក្រក់ រឿងវាទៅអីចឹងទៅ។

ដានី៖ ចុះតា នី កន ឬ នាយ កន?

ចៀម៖ នី កន។

ដានី៖ នី កន គាត់ខ្សែខាង សុន សេន?

ចៀម៖ បងបង្កើតរបស់គាត់ដែរ។

ដានី៖ សុន សេន បងគាត់បង្កើត?

ចៀម៖ បាទ!

ដានី៖ គាត់នៅក្រសួងការបរទេសដែរ?

ចៀម៖ គាត់នៅក្រសួងការបរទេសហ្នុង គាត់ទទួលខាងពិធីការ ចាងហ្វាងពិធីការ កាល៧៩ គាត់បោះមូលដ្ឋាននៅម៉កហ៊ុននេះគាត់ដឹកនាំទ័ពខាងនយោបាយផង ខាងយោធាផង បងហុងគាត់បើកច្រកតាំងពីកោះកុង ទៅទល់នឹងដែនឡាវ គាត់ដើរបើកច្រក តាមច្រកៗណា ហ្នឹងអឹ អៀង សារី ដើម្បីទាក់ទងកម្លាំងពីក្នុងចេញមក រៀបចំមូលដ្ឋានបង្អែកតាមជួរព្រំដែនទប់ទល់រដ្ឋាភិបាល អាហ្នឹងជាក់ស្ដែងវាអីចឹង។

ដានី៖ មួយទៀត ខ្ញុំចង់ដឹងពីការរៀបចំតំបន់ម៉ាខ្សែយើងណាអឹ?

ចៀម៖ បាទ!

ដានី៖ ម៉ាខ្សែយើងកាលពីដំបូង កាលកងទ័ពមិនទាន់មកដល់ កន្លែងហ្នឹងគេហៅអីគេ កាលពីមុននោះ?

ចៀម៖ នៅម៉ាខ្សែនេះ កន្លែងកងពល៨៥០ រៀបចំកងពល៨៥០ រៀបចំហ្នុងហើយ កងពលលេខ ៨៥០ គេហៅថាបើនិយាយពីសមរភូមិនោះកៀកខ្មាំងនោះ កៀកណាស់ហើយ ប៉ុន្តែខ្មាំង

ធ្វើអត់កើត វុញទៅ វុញមកៗ យើងធ្វើសគ្រាមអីចឹង ក្រោយពីនោះ អ៊ុនគាត់ទៀតយើងចូលធ្វើការតាមខាងក្នុងៗបានទាំងអស់ ដល់បានទាំងអស់អីចឹងអត់អីទេ ស្រួលម្យ៉ាងដែរ ។

ដានីៈ អឺ! ម៉ាឡៃយើងមុនពេលមកដល់ កន្លែងហ្នឹងកន្លែងស្អីគេទៅ គេហៅស្អីគេទៅ គេហៅម៉ាឡៃអីចឹងម៉ង?

ចៀមៈ កន្លែងហ្នឹងកាលហ្នឹងគេហៅ កន្លែងនេះកាលពាន្ឆាំខ្ញុំក្មេគេហៅថាភ្នំម៉ាឡៃៗ ភ្នំម៉ាឡៃនេះជាសំបុកខ្មែរសេរី កាលហ្នុងពួកដែកចាញ់យើង ឆ្នាំ១៩៧៥ ពួកតាឡៀង ឡៀល អិន តាំអីនៅហ្នុង ពួកហ្នឹងពួកខ្មែរស កាលជំនាន់ពាន្ឆាំខ្ញុំក្មេអីចឹង ពួកហ្នឹងវាមានចលនាវាធំ ទប់ទល់ជាមួយខ្មែរក្រហម ដល់ឆ្នាំ៧៩ ខ្ញុំមកនេះ គឺជាកន្លែងនេះ គឺព្រៃម៉ង សុទ្ធសឹងតែព្រៃព្រៃខ្លា ព្រៃដំរីម៉ង អត់មានអីចេះទេ ។

ដានីៈ មួយទៀតអឺ ភ្នំម៉ាឡៃ តំបន់ម៉ាឡៃ កាលពីជំនាន់ពាន្ឆាំស្ថិតនៅក្នុងគ្រប់គ្រងរបស់...

ចៀមៈ ភូមិភាគពាយ័ព្យ ។

ដានីៈ តំបន់ប៉ុន្មានទៅកន្លែងនេះ?

ចៀមៈ អានេះតំបន់៥ ។

ដានីៈ របស់ស្រុកអីគេទៅ?

ចៀមៈ កាលហ្នុងមែនទែនគេហៅតែស្រុកសេរីសោភ័ណ្ឌ ។

ដានីៈ មិនមែនស្រុកអូជ្រៅអីទេ?

ចៀមៈ អត់ទេ! អាហ្នឹងរដ្ឋកម្ពុជាបង្កើតក្រោយទេអាហ្នុងនោះ បើកាលនោះស្រុកសេរីសោភណ្ឌ័ ។

ដានីៈ តំបន់៥ មិនមែនតំបន់៣ទេ?

ចៀមៈ អត់ទេ! តំបន់៥ ។

ដានីៈ តំបន់៥ កាលហ្នុងពីណាគេគ្រប់គ្រង?

ចៀមៈ តំបន់៥ ហ៊ីង, ជៀល កូនតាញឹម ស្គាល់ទាំងអស់តើ តាវាញ យោធាបងឥសាន តាវាញ តាសម័យ តាស៊ូ តាគី តាគុល តាអីខ្វះទៀតច្រើន ។

ដានីៈ អីចឹងនៅម៉ាឡៃហ្នឹងកាលពីជំនាន់ពាន្ឆាំនៅក្នុងស្រុកសេរីសោភ័ណ្ឌ?

ចៀមៈ បាទ!

ដានីៈ គណៈស្រុកសេរីសោភណ្ឌ័ពីណាគេ?

ចៀមៈ តំបន់៥មាន ហ៊ីង មាន ជៀល ហ្នឹង ហើដល់ស្រុកមិនដឹងគេដាក់ម៉េច ខ្ញុំក្មេតែតំបន់៥ទេ ។

ដានីៈ អីចឹងកាលពីជំនាន់ពាន្ឆាំកន្លែងហ្នឹងជាកន្លែងពួកសេរីការ ពួកចោរព្រៃអីទេ?

ចៀមៈ បាទ! ពួកចោរព្រៃ ។

ដានីៈ វៃជាមួយកងទ័ពខាងខ្មែរក្រហម?

ចៀមៈ បាទ!

ដានីៈ តែពេលដែលក្រុមពួកអឹមកដល់ ពួកសេរីការ ពួកហ្នឹងអត់មានទៀតទេ?

ចៀមៈ បាទ! ពួកហ្នឹងអត់ឃើញទេ មិនដឹងថារត់ទៅណាទេ រត់ចូលថៃ ដល់ទៅកន្លែងហ្នុងឃើញគេហៅស្រះគៀសខ្លួនម៉ាកន្លែង កន្លែងហ្នុងគេហៅស្រះខ្មែរសេរី ដល់ទៅហ្នុងទៅគេហៅថាវាមានមូលដ្ឋានរបស់គេណា ទៅចក្រីទៅអីណា ឃើញមានហូហែរតាមហ្នឹង កន្លែងនោះវាលក់ឈើលក់អីទៅថៃ បានវាបានលុយកាក់ចាយវាយនោះណា ហ្នុងវាអីចឹង កាលមកហ្នុងខ្ញុំឃើញអីចឹង ។

ដានីៈ កន្លែងស្រះខ្មែរសេរី កន្លែងស្រះគៀសខ្លួនអីហ្នឹង អាហ្នុងកងទ័ពយើងមកក្រោយដាក់ ឬក៏យ៉ាងម៉េច?

ចៀមៈ ស្រះរបស់ខ្មែរសេរី គឺស្រះរបស់ខ្មែរយើងអ្នកដាក់ទេ ស្រះគៀស គឺជាពួកគៀសខ្លួនវាជីកទឹកហ្នុងវាប្រើណា ។

ដានីៈ គៀសខ្លួនទៅឆ្នាំណា?

ចៀមៈ ៧៩ ហ្នុង ពួកដែលចាញ់យើង ៧៩ហ្នុង ពួកហ្នុងវាចាញ់ វាមិនចូលព្រៃ នៅក្នុងព្រៃហើយបានវាទៅថៃ តាស្អី តាអិន តាំ អីមិនបង្កើតចលនាគេ តាអ៊ិន តាំ បង្កើតចលនាមូលីណាកា ។

ដានីៈ ចុះអឹ! ដល់ពេលក្រោយឆ្នាំ១៩៧៩ យើងបង្កើតក្រុមដឹកជញ្ជូន ក្រុមវៃអី យើងបង្កើតហ្នុង របៀបការគ្រប់គ្រងអីរបៀបយ៉ាងម៉េចទៅ របៀបគ្រប់គ្រងជាកងទ័ព ឬរបៀបគ្រប់គ្រងជាស៊ីវិល?

ចៀមៈ ជាកងទ័ព រស់នៅជាកងទ័ព គឺថាវាមាន មេពួក មេក្រុម អនុសេនាតូច អនុសេនាធំ វរៈសេនាតូច វរៈសេនាធំ បានកងពល ហើយបានសមរភូមិ ការរស់នៅរបៀបជាយោធាភាពភាវនីយកម្មម៉ង នៅប្រយ័ត្នប្រយែងជាប់ គ្រប់គ្រងផ្ទៃក្នុងរបៀបហៅថារបប២ណាប្រធាននយោបាយ និងប្រធានយោធា គឺថាមួយជំនាញខាងបញ្ជាយោធា មួយទៀតជំនាញខាងការប្រមូលកម្លាំងខាងនយោបាយ គ្រប់គ្រងកម្លាំង ទាំងមុខទាំងក្រោយ គឺនយោបាយ នយោបាយខាងមុខត្រូវ ធ្វើការងារជាមួយយុទ្ធជនខាងមុខ នយោបាយខាងក្រោយត្រូវធ្វើការងារជាមួយប្រជាជនខាងក្រោយ ដើម្បីឲ្យចូលរួមចលនាយើង ប្រជុំជីវភាព

អីចឹងណា ប្រជុំកម្លាំង... ក្រៅពីយើង...អីប្លែកៗយើង ត្រូវតាមដាន។

ដានី: កាលហ្នុងអឺ អៀង សារី គាត់គ្រប់គ្រងតំបន់បៃលិន និងតំបន់ម៉ាឡៃ?

ចៀម: បាទ!

ដានី: សុន សេន គាត់គ្រប់គ្រងតំបន់សំពៅលូន តំបន់ខាង...

ចៀម: ហ្នឹងហើយ

ដានី: នី កន អីខាងគាត់!

ចៀម: ហ្នុងហើយ! សុន សេន ដំបូងគាត់គ្រប់គ្រងខាង១០០១ និង១០០២។

ដានី: ១០០១, ១០០២ នៅឯណាទៅ?

ចៀម: នោះនៅជាប់ព្រះវិហារណុះ ជាប់ព្រំដែនឡាវណុះ ពីព្រោះកាលគាត់ចេញពីក្នុង គាត់ចេញប្រកហ្នុង ដល់ក្រោយមកទៀត គាត់មកបៃលិនដែរ គាត់មកបៃលិនទៅវាបញ្ហាគ្រប់គ្រងវាគេមិនបានទេ នៅនោះក៏គ្រប់គ្រងគេអត់បានដែរ អីចឹងមកដាក់ជាប់នៅជាមួយប្អូនគាត់នេះ បាទបងនី កន នេះ បានគាត់ក្តាប់កម្លាំងវៃបានណា បានគេឲ្យនៅខាងលិចនេះ ចាប់ពីផ្លូវលេខ៥ គេហៅសមរភូមិកម្ពុជាខាងលិច មានទួន ជា មាន សុន សេន អ្នកដឹកនាំខាងជើងនោះ មានតាម៉ុក នឹងកែ ពក អីនឹង ។

ដានី: ខាងជើងចាប់ពីណាទៅណា?

ចៀម: ខាងជើងគិតចាប់ពីខាងជើងប៉ោយបែតនេះទៅទល់ឥសាន ទៅទល់ព្រះវិហារទៅទល់រតនះគិរីមណ្ឌលគិរី អាហ្នឹងប៉ែតខាងកើត ខាងជើងប៉ែកខាងកើត អានេះខាងត្បូងខាងលិច គេចែកចេញសមរភូមិធំៗ២នេះ អ្នកដឹកនាំខាងនេះម៉ាកន្លែង ទៅខាងអន្លុងវែងមួយកន្លែង។

ដានី: ខាងអន្លុងវែងពីណាគេគ្រប់គ្រងកាលហ្នុង?

ចៀម: ប៉ុល ពត នៃ ខៀវ សំផនកាលហ្នុង

ដានី: ចុះខាងណេះ ខាងយើងនេះ...

ចៀម: ខាងយើងមានអឺ អៀង សារី។

ដានី: ខាងយើងខាងណា?

ចៀម: នៅកងពល ៤៥០ និងកងពលនៅប៉ៃលិន។

ដានី: នៅប៉ៃលិន កងពលលេខប៉ុន្មានហ្នុង?

ចៀម: កងពល ៤១៥ ហ្នុង អ៊ី ឈាន។

ដានី៖ សុន សេន ដល់ពេលគាត់រត់ ១០០១ និង ១០០២ ហ្នឹង មកនៅកន្លែងប្អូនគាត់ នី កន?

ចៀម៖ បាទ!

ដានី៖ នី កន គាត់បន្ទោះពីកន្លែងណាទៅកន្លែងណា?

ចៀម៖ នី កន មុខសញ្ញាគាត់គឺថា ចាប់ពី ចាក់ទៅបាត់ដំបង ទៅទន្លេសាប ។

ដានី៖ ចុះម៉ាឡៃ យើងពីត្រង់ណាទៅណា?

ចៀម៖ ម៉ាឡៃយើងចាប់ពីផ្លូវលេខ៥ មកទល់ខេត្តបាត់ដំបង មកទល់ទីរួមខេត្តបន្ទាយមានជ័យ ។

ដានី៖ ផ្លូវជាតិលេខ៥ ចាប់ពីម្តុំណាទៅ?

ចៀម៖ ចាប់ពីប៉ោយប៉ែតមកស្វាយស៊ីសុផុន... ។

ដានី៖ ចុះអ៊ីអៀង សារី ទីតាំងគាត់នៅឯណា ផ្ទះគាត់?

ចៀម៖ ផ្ទះគាត់នៅនេះតើស នៅឈត្រង់នេះ នៅម៉ាឡៃហ្នឹងឯង នៅម៉ាឡៃហ្នឹងម៉ាកន្លែង នៅប៉ៃលិនម៉ាកន្លែង ។

ដានី៖ អីចឹងគាត់ចល័ត គាត់នៅនេះខ្លះទៅ គាត់ទៅនៅណុះខ្លះទៅ?

ចៀម៖ គាត់ចល័ត! ហើយទទួលភស្តុភារដឹកជញ្ជូនពីក្រោមកលើគាត់ទាំងអស់ ស្បៀង ថវិការអីលើគាត់ទាំងអស់ ម៉ាកម្ពុជាហ្នឹង ។

ដានី៖ អីចឹងដល់ពេលនៅខាងក្នុង ដូចនៅក្នុងម៉ាឡៃយើង យើងគ្រប់គ្រងដឹកនាំពីណាខ្លះទៅ?

ចៀម៖ ម៉ាឡៃ មានបងសុខ ភាព ខាងយោធា បងសូ ហុង គាត់ខាងនយោបាយ ។

ដានី៖ ចុះ អ៊ំកាលហ្នុង?

ចៀម៖ ខ្ញុំនៅក្នុងហ្នុងដែរ ខ្ញុំកាន់កងពលដែរ កាន់ខាងភស្តុភារ នឹងដឹកជញ្ជូន ។

ដានី៖ កាន់ខាងភស្តុភារ និង ដឹកជញ្ជូន!

ចៀម៖ បាទ! វ៉ៃដែរ ។

ដានី៖ វ៉ៃដែរ ភស្តុភារ និងជញ្ជូនហ្នឹង?

ចៀម៖ បាទ! បើថា ដឹកជញ្ជូន បើថាមិនវ៉ៃមានផ្លូវណាទៅត្រូវវ៉ៃ ។

ដានី៖ ភស្តុភារ និងដឹកជញ្ជូន ភាគច្រើននារីៗ ឬយ៉ាងម៉េច?

ចៀម៖ អត់ទេ! គឺថាមាកងពលហ្នឹង ទាំងយោធានៅមុខ ទាំងយោធានៅខាងក្រោយគ្រប់គ្រងទាំងអស់ ដឹកជញ្ជូនគេគ្រប់គ្រង ខាងមុខយើងមានមុនសញ្ញាគ្រប់គ្រងមួយដែរណា ឧបមាថា យើងផ្តល់ ស្បៀង ផ្តល់គ្រាប់រំសេវគេណា យើងដឹកជញ្ជូនគេនៅហ្នុង ជញ្ជូនលាក់តាម

ព្រៃតាមអី គ្រាប់រំសេវ ស្បៀងអាហារអីហ្នុង រៀបចំអាហ្នឹងបានវ៉ៃបាន បើរៀបចំអាហ្នឹងមិនបានទេ មិនអាចវ៉ៃបានទេ ។

ដានីៈ ចុះកាលហ្នុងយើងដូចថា អឹខាងភស្តុភារ ខាងដឹកជញ្ជូនអីហ្នុង ដូចថាស្បៀងខាងណាខ្លះគេផ្តល់ឲ្យយើង?

ចៀមៈ ជំនួយ! ជំនួយចិនណា ចិនទាំងអស់ អង្ករ អំបិល គ្រាប់រំសេវចិនទាំងអស់ ថវិការចិនទាំងអស់ម្ហូបអាហារចិនទាំងអស់ ចិនទាំងអស់ ។

ដានីៈ ចុះខាងកាកបាទ ពួកខាងអន្តការ...?

ចៀមៈ អត់ទេ! អានោះខាងប្រជាជនដែលគេចូលជិវំ គេខាងមនុស្សធម៌ហ្នុងក៏មានដែរ ជិវំតាឌុកនេះ ជិវំខាងអ៊ីជាវ ជិវំស្រះកែវ ជិវំខាំ...មានកាលនោះ ។

ដានីៈ អីចឹងខាងកងទ័ពតស៊ូអី ចិនទាំងអស់!

ចៀមៈ បាទ!

ដានីៈ ចុះកាលហ្នុងដូចថាជំនួយ យើងវ៉ៃអី យើងប្រើគោលនយោបាយរបស់កងទ័ព យើងត្រូវវ៉ៃយើងវ៉ៃរបៀបយ៉ាងម៉េចវិញទៅ?

ចៀមៈ យើងវ៉ៃ! បើយើងស៊ើបការណ៍បានច្បាស់ យើងអាចវ៉ៃកម្ទេចបានយើងវ៉ៃកម្ទេសទីតាំងទៅណា ប៉ុន្តែបើយើងមិនទាន់ស៊ើបបានទេ ប៉ុន្តែយោធាវាបានជាមូលដ្ឋានវ៉ៃណា វ៉ៃរហ័សដករហ័សបាន ហើបន្ទាប់ពីហ្នឹង សង្គ្រាមឈ្លប សង្គ្រាមឈ្លបហ្នឹង ៣នាក់ក៏វ៉ៃបាន ២នាក់ក៏វ៉ៃបាន ៥នាក់ក៏វ៉ៃបាន ១០នាក់ក៏វ៉ៃបាន វ៉ៃដូចថាកប់មីន គ្រៀមកន្ទ្រាក់មីន អាហ្នឹងបានទាំងអស់ អត់ចោទទេ ហើបណ្តុះបណ្តាលកូនចៅប្រជាជនឲ្យចេះច្បាំង សូម្បីតែដែកគោលមួយដាក់តាមផ្លូវឡាន ឲ្យវាអាក់ខាននោះក៏ជាសង្គ្រាមឈ្លបមួយដែរ ។

ដានីៈ ដូចយើងរបៀបធ្វើចំរូង ជ័រឆក់អី?

ចៀមៈ បាទ! ចំរូងជ័រឆក់ អាហ្នឹងធ្វើបានទាំងអស់ ។

ដានីៈ កាលហ្នឹងធ្វើធ្វើរបៀបប៉េចទៅចំរូងជ័រឆក់ ខ្ញុំធ្លាប់តែឮពត៏មានហ្នឹង?

ចៀមៈ ចំរូងគឺយកឬស្សី បិតទៅណា ជ័រឆក់វាមានថ្នាំវា ថ្នាំជ័រឆក់វាលាយពិសពស់ ពិសស្អីដែលពិស។ គេស្ងួទៅគេដាក់ផ្សំនឹងឬស្សរឈើ គឺថារូបភាពដូចព្រួញហ្នុង... ចំរូងចាក់លាត់ក៏បានចាក់សាងក៏បាន ចំរូងអន្ទ្រប់ក៏បាន ចំរូងអណ្តុងក៏បាន មានច្រើនបែបច្រើនយ៉ាងទៀតអាហ្នឹងគេហៅសង្គ្រាមប្រជាជន អ្នកណាក៏ធ្វើកើតដែរ ស្រីក៏ធ្វើបាន ប្រុសក៏ធ្វើបាន ចាស់ក៏ធ្វើបាន ក្មេងក៏ធ្វើបាន ។

ដានី៖ យើងបង្រៀនឲ្យធ្វើ?

ចៀម៖ បង្រៀន! អាហ្នឹងគេហៅចលនាដាក់ស្តែង យើងថាយើងមានអីកន្លែងហ្នឹងយើងធ្វើកន្លែងហ្នឹង យើងមានស្មារតីអីចឹង អាហ្នឹងដូចថាគេជ្រួតជ្រាបគេ ឆាប់យល់ណា ដល់ឆាប់យល់ធ្វើកើត ដល់នេះគេមានជំនឿ ហើធ្វើទៅវាមានប្រសិទ្ធភាព បើថាចារកម្មមិន ឆាយចូលចុះទេ យើងដាក់មីនផង ឥឡូវវាមានមីនទំនើបទៀត អាមីនក្រោយមីនដាក់ទៅប៉ះផ្ទុះទៀត កាន់តែប្រសើរផ្នែកការពារណា ។

ដានី៖ ចុះអ៊ីពេលហ្នុងកងទ័ពអីចឹង ដល់ពេលនៅហ្នឹងសុទ្ធតែព្រៃអីចឹងយើងធ្វើផ្ទះ ធ្វើជម្រកអីយ៉ាងម៉េចទៅ?

ចៀម៖ អត់ទេ! អត់មានផ្ទះអីចេះទេ អត់មានទេ កាលហ្នុងមានតែដំបូងមានតែឫស្ស ធ្វើអំពីឫស្សីធ្វើអំពីស្បូវអីចឹងទៅណា ហើធ្វើតង់ខ្លះទៅណា បើប្រជាជនគេនៅខាងក្រោយ គេក្រងស្បូវគេធ្វើ តូចៗម៉ាគ្រែៗហ្នុង មួយគ្រែម្នាក់ៗ ធ្វើតូចៗនៅអីចឹងទៅណា ។

ដានី៖ នៅតាមណាទៅ?

ចៀម៖ នៅតាមព្រៃហ្នឹង ចេះតែដំរៀបហែៗទៅ និយាយរួមតាមមាត់អូហ្នឹង ។

ដានី៖ តាមមាត់អូហែៗ! ច្រើនទេកាលជិនទំហ្នុងទាំងកងទ័ពទាំង...ប្រហែលប៉ុន្មានដែរ?

ចៀម៖ គ្នា២,៣ ម៉ឺននាក់ដែរ ។

ដានី៖ ច្រើនដែរ!

ចៀម៖ ច្រើន! បើនិយាយពីសាច់ទ័ព ទាំងប្រជាជនទាំងទ័ពកាលហ្នុងរាប់លាន់ដែរណា មិនឆាយសាបរលាបទេ មិនឆាយទេ សង្គ្រាមឈ្លបតស៊ូប៉ុន្មានរយឆ្នាំក៏មិនចប់ដែរ ។

ដានី៖ ប្រយើងសរុបទាំងអស់រាប់លានដែរ?

ចៀម៖ បាទ! ការកសាងកម្លាំង ទីក្រុងក៏គេធ្វើកើត ទីប្រជុំជន់ក៏គេធ្វើកើត ទីជនបទក៏គេធ្វើកើតនៅទន្លេក៏គេធ្វើកើត នៅឯណាក៏ធ្វើកើតទាំងអស់ ។

ដានី៖ ចុះអ៊ីបើតាមខ្ញុំស្តាប់ពូមីងគាត់មានប្រសាសន៍ប្រាប់ខ្ញុំថា កាលពីឆ្នាំ៨៩ មានយួន និងកងទ័ពខាងរដ្ឋកម្ពុជាគេវៃចូលមកដល់ទីហ្នឹងដែរ?

ចៀម៖ បាទ! ចូល ធ្លាក់ទៅដីថៃទាំងអស់ ។

ដានី៖ ម៉េចបានយើងទប់អត់បានបណ្តោយឲ្យចូលមកកាលហ្នុង?

ចៀម៖ បាទ! ទប់អត់បានទេ គឺថាអីចេះ បើថាកម្លាំងស្រួចណា យើងមិនអាចទប់បានទេ យើងជៀសសិន បើយើងទប់យើងខ្ទេចកម្លាំង យុទ្ធសាស្ត្រមួយអាហ្នឹង បើទប់ទល់មុខដឹងតែពីខ្ទេចហើយ

កុំទៅទប់ ឲ្យវាទៅតាមដំណើររឿងវាអីចឹងទៅ ចាំយើងទៅវ៉ៃកាត់ជាកង១ យើងទៅវ៉ៃរំដោះឆ្នាំ៨៩នៅភ្នំម៉ាឡៃហ្នឹង យើងវ៉ៃរួមអត់បានទេណា យើងទៅវ៉ៃនៅផ្លូវតើស វ៉ៃនៅផ្លូវមួយថ្ងៃ២០ដងទៅ៣០ដងទៅណា ហើយវ៉ៃហ្នឹងគ្នា២នាក់ ៣នាក់ទេ វ៉ៃល្បបហ្នឹង វ៉ៃកន្ទ្រាក់មីន គេវ៉ៃកន្ទ្រាក់មីនហ្នឹងគេមានរបៀបវិន័យរបស់គេ វ៉ៃហើយគេកន្ទ្រាក់មីនអត់ឲ្យបាញ់ទេ បាញ់ខ្ទាចវាពួសូជីងទិសដៅណា កន្ទ្រាក់តែមីន វាផាប់របួស១ ណាហិននៅតាមភ្នំរត់ដូចហ្នឹងគោអីចឹង រត់ដូចហ្នឹងគោបើវាដាច់ស្បៀង ដាច់ការទាក់ទងហើយមានស្អីទៀត ទូរសព្ទ័យើងកាត់ផ្តាច់ យើងលួចស្តាប់ ។

ដានី: ចុះកាលយើងទៅ កាលយួនចូលមកយើងទៅថៃ យើងទាក់ទងយ៉ាងម៉េច បានជាយើងអាចទៅ នៅដីថៃបាន?

ចៀមៈ យើង ខាងលើយើងទាក់ទងជាមួយខាងលើគេទៅ ។

ដានី: គេឲ្យយើងនៅម្តុំណា?

ចៀមៈ គេឲ្យយើងនៅតើស! យើងនៅដីគេ យើងជួលដីគេនៅទៅណា ។

ដានី: គេហៅអីគេម្តុំហ្នឹង?

ចៀមៈ គេហៅ ៨៥, ៨៦ ដង ។

ដានី: ច្រើន! កាលយើងទៅនៅដីគេ?

ចៀមៈ រាប់ម៉ឺននាក់ដែរ ។

ដានី: ក្រោយមកកងទ័ពយើងចេញមកស្នាក់វ៉ៃឆ្នក់ដូចដែរអឹមានប្រសាសន៍មិញ?

ចៀមៈ បាទ! យើងវ៉ៃបានមូលដ្ឋាន រំដោះបានឆ្នាំ៩០នេះ ។

ដានី: ឆ្នាំ៩០ បានយើងចូលមកវិញ?

ចៀមៈ បាទ! ឆ្នាំ៩០តើស អាហ្នឹងគឺថាមីង១កូនចៅអីណានៅដីថៃ ហីកងទ័ពកសាងមូលដ្ឋានទៅវ៉ៃកាលហ្នឹងវ៉ៃព្រំដែនអត់បាន ទៅវ៉ៃនៅអន្តរបុរីវិញណុះ វ៉ៃស្មាយវិញ បានកកម្លាំងវាដកថយមកវិញ បានវាទូលាយកន្លែងនេះ យើងមានកម្លាំងរបស់យើងបង្កប់នៅកន្លែងនោះដែរ យើងវ៉ៃកាន់កាប់ស៊ីសុផុន អន្តបុរីមួយវគ្គដែរ ដល់ធ្វើយូវាផ្អើលដែរណា ដល់កម្លាំងខ្ញុំនៅទន្លេសាបទៀត ដល់វ៉ៃកន្លែងនេះ វ៉ៃកន្លែងនោះវា...

ដានី: បានយើងទូលាយ យើងចូលមកវិញនៅឆ្នាំ៩០ហ្នឹង!

ចៀមៈ ឆ្នាំ ៨៩ ខែ១១ ថ្ងៃ១៥ យើងវ៉ៃរំដោះមានផ្លូវហ្នឹងអស់រលីញម៉ង នៅតែទីរួមស្រុកនៅតាមផ្លូវលេខ៥ នៅបៀយបែត ហីនៅស៊ីសុផុនអីចឹងទៅ ហីព្រៃយើងកាន់កាប់ទាំងអស់ ។

ដានីៈ អីចឹង ថ្ងៃ១៥ ខែ១១ ឆ្នាំ៨៩ យើងវ៉ៃបានកាន់កាប់!

ចៀមៈ បាទ!

ដានីៈ ចុះអឹយើងចូលមកវិញ ដូចថាផលវិបាកយ៉ាងម៉េចខ្លះ ពេលដែលយួនគេដកទៅវិញ ខាងរដ្ឋកម្ពុជាគេដកទៅវិញហើយ ដូចថាផលវិបាកយ៉ាងម៉េចខ្លះដែលបន្សល់នៅពេលយើងចូលមកវិញ?

ចៀមៈ ចូលមកវិញ ដូចថាម៉ាខ្សែព្រំដែននេះ គឺថាបង្កប់មីនទាំងអស់ ហៅថាកំណែន ក៥ នោះណាបង្កប់មីន ដាក់ចំរូងដែក បង្កប់មិនហើយធ្វើរនាំងដែកទៀត ។

ដានីៈ ចុះយើងធ្វើម៉េចទៅ យើងដើម្បីសំអាត...

ចៀមៈ ដោះខ្ទេច ដោះមីនហ្នឹង ដោះអាបន្ទោលដែកហ្នុងលក់អស់រលីញ អាបន្ទោលដែកហ្នឹងដែកថែលក់ឲ្យបានលុយចាយ ហីមីនហ្នុងដោះ ។

ដានីៈ ចុះកាលហ្នុងមានគ្រោះថ្នាក់ច្រើនទេ បើស្ថិតីអឹ?

ចៀមៈ មានគ្រោះច្រើន ។

ដានីៈ ច្រើនហ្នុងប៉ុន្មាន គ្រោះថ្នាក់ដោយសារមីន ដោយសារ...

ចៀមៈ រាប់រយ...

ដានីៈ រាប់រយដែរ!

ចៀមៈ ស្លាប់ ហើយរបួសទៀត ពិការទៀត ។

ដានីៈ អីចឹងតាំងពីយើងគ្រប់គ្រងឆ្នាំ៩០ហ្នុង ខាងណុះអត់ដែលមានចូលមកយើងវិញទេ?

ចៀមៈ អត់ទេ! អត់មានទេ ចូលមកឆ្នាំ៩០ ហី២៣ តុលា ឆ្នាំ៩១ ហ្នុងមានកិច្ចព្រមព្រៀងហ្នុងយើងបញ្ចូលកម្លាំងយើងនៅភ្នំពេញមានហើយ... ពេលនោះសូម្បីតែវ៉ៃក្បាលអឹ ខៀវសំផន ហ្នុង កម្លាំងយើងនៅតែមានដែរ ។

ដានីៈ កម្លាំងយើងបង្កប់នៅភ្នំពេញដែរ?

ចៀមៈ មាន!

ដានីៈ ចុះអឹពេលយើងបែងចែកជាភូមិ ជាឃុំ ជាស្រុកអីនោះ ដូចថារចនាសម្ព័ន្ធហ្នុងយើងចាប់ផ្តើមបង្កើតពេលណាអឹ?

ចៀមៈ នៅស្រុកម៉ាឡៃ យើងផ្ដាច់ នៅថ្ងៃទី១៥ សីហា ឆ្នាំ ១៩៩៦ យើងរៀបចំផ្ដាច់ខ្លួនទៅ យើងបង្កើតចលនាបង្រួបបង្រួមជាតិកម្ពុជាប្រជាធិបតេយ្យ យើងបានបង្កើតចលនាហ្នឹង ចលនាផ្ដាច់ខ្លួន ដល់យើងផ្ដាច់ខ្លួនបាន... ចុងក្រោយដល់ឆ្នាំ៩៨ វាបានទៅខាងអន្លង់វែង ខ្ញុំកាលពីឆ្នាំ៩៧ ខាងរដ្ឋាភិបាលបញ្ជូនខ្ញុំឲ្យទៅស្ទឹងត្រែង ភូមិភាគ១ ស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ ឲ្យទៅបំផុសចលនាផ្ដាច់ខ្លួននៅហ្នុងទៀត ខ្ញុំប៉ុន្មានខេត្តហ្នឹង ៦ខេត្តហ្នឹង ចលនាផ្ដាចខ្លួនហ្នុងអស់បានខ្ញុំវិញមកនៅម៉ាឡៃវិញ បេសកម្មខាងរដ្ឋាភិបាលបញ្ជូនខ្ញុំទៅនោះ សមរភូមិវាលឿន យើងទៅហ្នុងវាលឿនម៉ង។

ដានីៈ កាលហ្នុងខាងហ្នុង គ្រប់គ្រងដោយពីណាគេ?

ចៀមៈ គ្រប់គ្រងវាមានឆែ នៅភូមិភាគមេធំជាងគេឈ្មោះ យ៉ា ដែលកាន់ឋានៈភូមិភាគណាម៉ាភូមិភាគឥសាន ខាងខ្មែរក្រហមគឺគាត់។

ដានីៈ ឈ្មោះ យ៉ាន!

ចៀមៈ យ៉ា! ឥឡូវគាត់ធ្វើរងមេស៊ុបខេត្តរតនៈគិរី គាត់សក្តិ ៥ គាត់ត្រូវជាបងប្អូនខ្ញុំ ចលនាអូសទាញបានមកទាំងអស់។

ដានីៈ អ៊ីខ្ញុំចង់ដឹងមួយទៀតនៅខាងម៉ាឡៃយើងមានបែកដូចជាមានភូមិដូង ភូមិកណ្ដាល ភូមិស្អីហ្នុងគេបែកយ៉ាំងម៉េច ទៅអាហ្នុង?

ចៀមៈ ហ្នុងហើយ កាលមុនយើងរៀបចំហ្នុងដូចវរៈសេនាតូច វរៈសេនាធំ អីចឹងណា វរៈសេនាតូចនេះ វរៈសេនាធំនេះ គឺបែងចែកទៅជាភូមិ ក្នុងឋានៈជាកងពល គឺថាអគ្គរក្សជុំវិញ កងពលនោះ ក្នុងម្នាក់ៗ ខ្ញុំអងរក្សខ្ញុំ១០០នាក់ជាង ខ្ញុំរៀបចំជាភូមិមួយ។

ដានីៈ បាទ! ភូមិអីគេហ្នុង?

ចៀមៈ ហ្នុងរាល់ថ្ងៃនៅឃុំទួលពង្រ ភូមិនោះរៀបចំជាភូមិស្មើមានជ័យ ភូមិសន្តិភាព ភូមិបន្ទាយទី១ ភូមិទួលពង្រ ភូមិខ្វាងរាប ភូមិកោះស្នួល ភូមិអូសំព័រ១ ភូមិអូសំព័រ២ ភូមិបន្ទាយទី២ ដល់រៀបចំអីចឹង ប៉ុន្មានភូមិ ទៅជាឃុំមួយ។

ដានីៈ ម៉ាភូមិស្មើហ្នឹងអី?

ចៀមៈ ដូនណា៨ភូមិស្មើនឹងមួយឃុំ, ៨ភូមិ ស្មើនឹងមួយឃុំ នៅនេះវាមាន៥ភូមិស្មើនឹងមួយឃុំដែរ ម៉ាស្រុកម៉ាឡៃវាមាន៦ឃុំ ឃុំបឹងបេង ឃុំម៉ាឡៃ ឃុំអូរស្រឡៅ ឃុំអូរសំព័រ ឃុំទួលពង្រ និងឃុំតាគង់។

ដានី៖ ប៉ុន្តែយើងបែងចែកដំបូង ដោយសាកលទ័ពយើងបោះទីតាំងនៅកន្លែងណា យើងចែកជាភូមិឲ្យគាត់នៅទៅ?

ចៀម៖ ហ្នឹងហើយ! កន្លែងយើងតស៊ូនៅត្រង់ណាចែកទៅ យើងចែកយើងចូលរដ្ឋាភិបាលយើងបែងចែកកម្លាំងមួយចំនួនគឺធ្វើយោធាតទៅទៀត ហើកម្លាំងមួយចំនួនធ្វើ ប៉េ អឹម ធ្វើប៉ូលីស ហើកម្លាំងមួយទៀតធ្វើស៊ីវិលធ្វើអភិបាលស្រុក អភិបាលរង មានការយាល័យនេះ ការិយាល័នោះអីចឹងទៅ គេចាត់តាំង រចនាសមព័ន្ធពីលើមកម៉េចរៀបចំដូចខាងក្នុងដែររៀបចំអស់ ។

ដានី៖ ប៉ុន្តែអ្នកខាងក្នុងគេអត់មករៀបចំឲ្យយើងទេ យើងជាអ្នករៀបចំបែងចែកដោយខ្លួនឯង?

ចៀម៖ អត់ទេ! គេគ្រាន់តែប្រាប់យើង គេគ្រាន់តែមកប្រាប់យើង គេមកពិភាក្សាជាមួយយើងថា យើងមានប៉ុន្មានភូមិ យើងប្រាប់ទៅថាមានប៉ុន្មានភូមិ ហើយើងចង់បង្កើតប៉ុន្មានឃុំ យើងប្រាប់គេតាមហ្នឹង តាមភូមិសាស្ត្ររបស់យើង យើងក្តាប់បាន ហើយើងបង្កើតជាស្រុកមួយខាងលើគេអូយទៅ ចេញប្រកាជក្រិត្យមួយទៅ ហើយអភិបាល អភិបាលរងហ្នឹងយើងតែងតាំងហើយស្រេច ។

ដានី៖ តែងតាំងខ្លួនយើង យើងរៀបចំ?

ចៀម៖ ខ្លួនយើងទាំងអស់ តាមឋានានុក្រមរបស់យើង បញ្ជូនទៅលើទៅ យើងឯកភាពទៅយើងគ្រង់គ្រង ។

ដានី៖ អីចឹងកាលហ្នឹងយើងដូចថាភូមិមួយស្មើនឹងស្អី ដូចថាមួយអនុសេនាធំ ឬវរៈសេនា...?

ចៀម៖ ភាគច្រើនវរៈសេនាតូច ហើនិងអនុសេនាធំ ។

ដានី៖ មួយវរៈសេនាតូច ស្មើភូមិមួយ?

ចៀម៖ បាទ! បើមួយវរៈសេនាធំវាទៅជាឃុំមួយ ចំណុះឲ្យកងពលហ្នឹងវាទៅវាហៅថាមេមួយភូមិមួយដែរ ។

ដានី៖ ចុះឈ្មោះហ្នឹង កាលពីមុនមកមានឈ្មោះហ្នឹងដែរអត់ កាលមុនផ្តាច់ខ្លួនណា ដូចជាឃុំម៉ាឡៃយើងវាមានភូមិដូង ភូមិកណ្តាល ភូមិថ្មី....

ចៀម៖ អត់! អត់ទាន់មានទេ ដល់យើងផ្តាច់ខ្លួនយើងរៀប យើងដាក់តាមភូមិសាស្ត្ររបស់យើងដែលយើងក្តាប់បានអស់ហើយ ឧបមាថាភូមិទួលពន្រ វាមានដើមពន្រនៅកន្លែងហ្នឹង ភូមិកោះស្នួល វាមានដើមស្នួលនៅកន្លែងហ្នឹង ភូមិបន្ទាយទី១ វាមានបន្ទាយទី១ នៅកន្លែងអីចឹងទៅ ដូចថាឃុំបឹងបេង នៃវាមានភូមិសង្កែ ដើមសង្កែនៅហ្នឹងទៅ ហើភូមិចំបក់វាមានដើមចំបក់នៅហ្នឹងទៅ ភូមិល្មុវាមានដើមល្មុនៅកន្លែងហ្នឹងអីចឹង ។

ដានី៖ អូ! គេរៀបចំអីចឹងទៅ?

ចៀម៖ បាទ! រៀបចំអីចឹងទៅ។

ដានី៖ ហើដូចជាយើងបែងចែកដូចថាអ្នកខ្លះទៅធ្វើយោធាដដែល អ្នកខ្លះមកធ្វើរដ្ឋបាល ដូចជាយើងបែងចែកជាអភិបាល អភិបាលរងអីចឹង ខាងប៉ូលីសខាងអីដូចថាយើងបែងចែកម៉េចទៅ?

ចៀម៖ យើងបែងចែក ឧបមាខ្ញុំក្នុងឋានៈកងពលហ្នឹង គឺខាងគណៈស្រុក អភិបាល ឬអភិបាលរងអីចឹងទៅណា។

ដានី៖ ហ្នឹងគណៈកងពល?

ចៀម៖ បាទ! ហើគណៈកងពលខាងសមរភូមិហ្នឹងរៀបចំជាកងពលមួយអីចឹងទៅ ឧបមាថាកងពល ៤៥០ប្រែមកគេដាក់កងពល២១ ប្រែពីកងពល២១ ឥឡូវកងពល៥១ អីចឹងរាល់ថ្ងៃ។

ដានី៖ អីចឹងមកខាងស៊ីវិល?

ចៀម៖ ខាងស៊ីវិល។

ដានី៖ ខាងអភិបាល អភិបាលរងវិញ!

ចៀម៖ បាទ!

ដានី៖ កាលហ្នឹងអភិបាល គាត់ឈ្មោះអីទៅ?

ចៀម៖ កាលបង្កើតឆ្នាំ ៩៧ហ្នឹង ឈឹម មុនី ឥឡូវគាត់នៅការិយាល័យនៅសាលាខេត្ត។

ដានី៖ កាលពីមុននោះគាត់ទទួលខាងអីដែរ?

ចៀម៖ គាត់ហ្នឹងខាងនយោបាយដែរ។

ដានី៖ អភិបាលរងមានប៉ុន្មាននាក់កាលជំនាន់អឹ

ចៀម៖ អភិបាលមាន៣នាក់ មានខ្ញុំ មាន ...ម៉ុន និង ...ម៉ន មាន៣នាក់ អភិបាលស្រុក ឈឹម មុនី។

ដានី៖ ដល់ពេលខាងប៉ូ លីស យ៉ាងម៉េចដែរខ្ញុំអត់ដឹង ដូចថាយើងបែងចែកយ៉ាងម៉េចខាងប៉ូ លីសហ្នឹង!

ចៀម៖ ខាងប៉ូ លីស ថ្នាក់ស្រុកហ្នឹងគេហៅអធិការ អធិការរង តាមឃុំហ្នឹងគេហៅថាមេប៉ុស្តិ៍ ម៉ាឃុំ ៩នាក់ទេ មួយឃុំ៩នាក់ៗគេប៉ុស្តិ៍។

ដានី៖ បាទ!អាហ្នឹង ប៉ុន្តែកាលពីមុនយើងសមាហរណកម្មយើងអត់មានប៉ូ លីសទេឬ?

ចៀម៖ អត់មានទេ!

ដានី៖ ប៉ុន្តែយើងយើងជ្រើសរើសអ្នកណា មានសមត្ថភាពយ៉ាងម៉េចឲ្យមកធ្វើប៉ូ លីសវិញ?

ចៀម៖	យើងចេញពីវរៈសេនាតូច ភាគច្រើនប៉ូ លីស ចេញពីវរៈសេនាតូច។

ដានី៖	មកធ្វើអធិការ អធិការរង!

ចៀម៖	បាទ!  អធិការ អធិការរង។

ដានី៖	ចុះប៉េអឹម!

ចៀម៖	ប៉េ អឹម ក៏ដូចគ្នា! យោធាស្រុក ក៏ដូចគ្នា ប៉េអឹម ប៉ូ លីស ហ៊ីនិងយោធាស្រុក ដូចគ្នា ស័ក្តដូចគ្នាទៀត រដ្ឋាភិបាលឥឡូវគេឲ្យស័ក្តដូចគ្នា។

ដានី៖	ខាងអភិបាលស្រុកយ៉ាំងម៉េច ពេលក្រោយមកយើងមានបោះឆ្នោត ឬអត់ទេ បានមានការផ្លាស់ប្តូរ?

ចៀម៖	អត់ទេ! ដល់អណ្តិអត់មានបោះឆ្នោតអីទេ គេតែងតាំង ឧបមាថាអ្នកដែលចូលដល់វ៉ីគ្រែត ហើយ គេជ្រើសរើសឡើងទៀតទៅណា។

ដានី៖	គេគិតតាមអាយុឬម៉េចអាហ្នឹង?

ចៀម៖	អត់ទេ! ឧបមាថាខាងក្នុងមក៨នាក់ហើយតើសឥឡូវ ...យី ...សុខា ...កែវ រ៉ា ...មកបួននាក់ ប៉ុនអភិបាលរងទាំងអស់ក្រោយៗណា...។

ដានី៖	អ្នកមកពីខាងក្នុងមក?

ចៀម៖	បាទ! អភិបាលរងទាំងអស់ អតីតសល់តែ៣នាក់ទេ គណៈអភិបាលស្រុកហ្នឹងមានគ្នា៣នាក់ទេ អភិបាល និងអភិបាលរង២នាក់ នៅក្នុងហ្នុងគេជ្រើសរើសស្រីមួយ... ឥឡូវវ៉ាមានក្រុមប្រឹក្សាស្រុក។

ដានី៖	ក្រុមប្រឹក្សាស្រុកហ្នឹងគ្នាច្រើនទេអី?

ចៀម៖	នៅហ្នឹងគ្នា១៣នាក់ គណបក្សប្រជាជន១២នាក់ គណៈបក្សសម រង្ស៊ី មួយ ១៣នាក់។

ដានី៖	កាលហ្នឹងអឹមានឈ្មោះនៅក្នុងហ្នឹងដែរ?

ចៀម៖	ខ្ញុំអត់ទេ! ខ្ញុំគេឲ្យចូល ប៉ុនខ្ញុំអត់ចូល ហត់ណាស់បានហើយ ឲ្យគេដឹកនាំចុះ។

ដានី៖	អ៊ឹនៅតែក្នុងបក្សទេឥឡូវ?

ចៀម៖	បាទ! នៅតែក្នុងបក្ស។

ដានី៖	អ៊ឹដូចថា បន្ទាប់ពីយើងសមាហរណកម្មមកដល់ឥឡូវ អ៊ឹគិតថាមានការប្រែប្រួលអ្វីដែរ កាលពីជំនាន់យើងតស៊ូពី៧៩រហូតមកដល់សមាហរណកម្ម ហ៊ីពីក្រោយសមាហរណកម្មមកមានការប្រែប្រួលម៉េចដែរនៅតំបន់ម៉ាឡៃយើង?

ចៀមៈ ឃើញវាល្អហើយដល់យើងចូលមកជាមួយរដ្ឋាភិបាល របូនាសម្តន័្ធរបស់យើងគឺនៅដដែល ទាំងអស់អត់អីទេយើងគ្រប់គ្រងខ្លួនយើងទាំងអស់ណា ឃើញថាវាល្អដែរ ឃើញថានយោបាយឈ្នះៗរបស់សម្តេច ហើសេចក្តីសន្យារបស់សម្តេចទាំងអស់ គឺថារដ្ឋាភិបាលធ្វើបានល្អ អត់មានបញ្ហាអីទេ ពីរឿងចលនៈទ្រព្យរបស់យើងក៏អត់មានប៉ះពាល់ ដីធ្លីរបស់យើងក៏អត់មានប៉ះពាល់ ផ្ទះសម្បែងយើងក៏អត់មានប៉ះពាល់ របស់យើងទាំងអស់ ការគ្រប់គ្រងខ្លួនយើងទាំងអស់ភ្ជាប់តែជាមួយរដ្ឋាភិបាល ឃើញស្រួលដែរ ស្រួលម្យ៉ាងដែរ អត់អីទេ ក្រៅពីហ្នឹងតាមភូមិតាមឃុំ ឥឡូវដល់គ្រប់គ្រងរបៀបវិមជ្ឈការណាឃើញវាល្អដែរ ល្អត្រង់ថាភូមិគេមានតួនាទីរបស់គេ ភូមិមាន៣ដែរឥឡូវ មេភូមិ អនុភូមិ ហើជំនួយការភូមិ ៣នាក់អាហ្នឹងភូមិ ហើឃុំវាមានមេឃុំ ហើយវាមានក្រុមប្រឹក្សាឃុំ វាល្អដែរ ដល់ស្រុកវាគណៈអភិបាលស្រុក និងមានក្រុមប្រឹក្សាស្រុក គេធ្វើល្អតាមរចនាសម្ព័ន្ធហ្នឹងគេធ្វើល្អ ការក៏ទៅតាមហ្នឹង ក៏មានការឯកភាពគ្នាទៅវាល្អម្យ៉ាងដែរ?

ដានីៈ ចុះលោកអភិបាលស្រុក កាលពីមុនមកគាត់មានតួនាទីអីដែរ កាលជំនាន់អឹជាអភិបាលរងហ្នឹង?

ចៀមៈ រាល់ថ្ងៃហ្នឹង បង ទេព ឃុនណាល់!

ដានីៈ បាទ!

ចៀមៈ កាលមុន បងទេព ឃុនណាល់ គាត់លេខាប៉ុល ពត ផ្ទាល់ ។

ដានីៈ គាត់នៅតំបន់ម៉ៅឡៃយើងដែរ?

ចៀមៈ អត់ទេ! គាត់នៅអន្លង់វែងណុះ ទើបមកនេះ៩៩ទេ ។

ដានីៈ គាត់មកឆ្នាំ៩៩!

ចៀមៈ ខាងលើគេទាញគាត់ទៅខាងលើ ប៉ុនគាត់អត់ព្រមទៅ ។

ដានីៈ គេទាញគាត់ទៅណា?

ចៀមៈ គេទាញគាត់ទៅខាងគណៈរដ្ឋមន្ត្រីណុះ ខាងរដ្ឋមន្ត្រីណុះ ។

ដានីៈ ប៉ុនគាត់អត់ទៅ!

ចៀមៈ គាត់ទៅ! គាត់សុំសម្តេច គាត់សរសេរទៅសម្តេចត្រង់ សុំនៅមូលដ្ឋានចុះ នៅស្រុកចុះ គេក៏ឲ្យតាម សំណូមពររបស់គាត់ទៅណា ហើយគាត់ក៏មានសមត្ថភាពល្អដែរ ។

ដានីៈ គាត់រៀនសូត្របានច្រើនដែរ?

ចៀមៈ បាទ! រៀនបានចេះដឹងច្រើនដែរ ។

ដានីៈ គាត់ចំណាស់ណាហើយឥឡូវ ខ្ញុំអត់ដែលបានជួបគាត់?

ចៀមៈ គាត់ប្អូនខ្ញុំទេ ប្រហាក់ប្រហែលគ្នា ។

ដានីៈ ចុះអ៊ីដូចថាចំណុចល្អកាលពីមុនយើងធ្វើសមាហរណកម្ម ចំណុចល្អយើងមានអី ចំណុចខ្វះខាតយើងមានអីខ្លះទៅ?

ចៀមៈ មុនសមាហរណកម្ម វាតូចចង្អៀតវាអត់ទាន់ទូលាយទេណា ព្រួយបារម្ភទៅតាមសង្គ្រាម អារម្មណ៍ទៅតាមសង្គ្រាម ទៅណាមកណាវាមិនបានទេ ឥឡូវយើងនៅអីចឹងទៅ វាជួបជុំកូនចៅជួបជុំប្រពន្ធកូនយើងខំតែរកស៊ី បង្កបង្កើនផលទៅតាមលទ្ធភាព ទៅតាមសមត្ថភាពរបស់យើងទៅ វាម្យ៉ាងដែរ ហើទៅណាមកណាយើងគ្មានភ័យព្រួយទៀតទេ ឲ្យតែមានលុយចេះតែទៅៗ ទៅស្រុកប៉ុន្មានដងក៏បានដែរ ចង់ទៅលេងឯណាក៏បានដែរ ស្រួលអីចឹងដែរ ។

ដានីៈ ចំណុចខ្វះខាត ឥឡូវបើយើងនិយាយពីចំណុចអសកម្មវិញវាមានដែរអត់?

ចៀមៈ ចំណុចអសកម្មនេះ គឺថា បញ្ហានៅម៉ាខ្សែនេះ សេចក្តីត្រូវការ វានៅបញ្ហារឿងផ្លូវណា វាមិនទាន់បានល្អ ផ្លូវនេះវាមិនទាន់បានល្អ ប៉ុនឥឡូវនេះវាមានគម្រោងធ្វើហើយ នៅផ្លូវទៅចំការតើស បើមានផ្លូវទៅចំការបាន ហើដោះស្រាយរឿងធរាសាស្ត្របានទៀត ម៉ាខ្សែនេះបោះជំហានទៅមុខហើយ ពីព្រោះរចនាសម្ព័ន្ធវាមានអស់ហើយ សាលារៀនក៏មានហើយ មណ្ឌលសុខភាពក៏មានហើយ ការយាល័យនេះ ការិយាល័យនោះក៏មានហើយក្នុងស្រុកនោះណា មិនមានជាបញ្ហាចោទទេ ហើជាការយល់ដឹងអីនោះ ច្បាប់ទម្លាប់អីនោះ សិទ្ធមុនស្សអីនោះដូចថាវាទូលាយម្យ៉ាងដែរ ។

ដានីៈ ចុះអ៊ីខស្សប្រាហ៍ទៅលេងស្រុកក្រោយនេះហើយ ឬក៏អ៊ីធ្លាប់ទៅលេងស្រុកកំណើតអ៊ីតាំងពីជំនាន់៣ឆ្នាំអីមក?

ចៀមៈ ៣ឆ្នាំអត់បានទៅទេ!

ដានីៈ ឆ្នាំណាបានអ៊ីទៅលេងស្រុក?

ចៀមៈ ទើបទៅបានឆ្នាំ៩៧ ឆ្នាំ៩៧ខ្ញុំជិះកប៉ាល់ហោះទៅទៀត ពីភ្នំពេញទៅចុះនៅរតនៈគិរី ។

ដានីៈ អូ! ដូចថាអ៊ីមានតួនាទីយើងទៅបង្រួបបង្រួមអីហ្នឹងឬ?

ចៀមៈ បាទ! ខ្ញុំទៅធ្វើបង្រួបបង្រួមអីហ្នុងបានហើយ បានខ្ញុំទៅលេងស្រុក ។

ដានីៈ ចុះអ៊ីប្លែកម៉េចដែរអ៊ី បែកពីស្រុកកំណើតយូ!

ចៀមៈ ប្លែកដែរ ពីដើមមនុស្សតែ៣ម៉ឺនទេ ឥឡូវវាឡើងជិត២សែនហើយ ។

ដានីៈ នៅឯណា នៅរតន្នគិរី?

ចៀមៈ ហ្នឹងហើយ ។

ដានីៈ ប៉ុន្តែ នៅភូមិ យុំម៉ង!

ចៀមៈ ភូមិអឹកឹវាប្រែក ក៏ប៉ុន្តែមិនជាប្រែកណាស់ណាទេ ក៏ប៉ុន្តែមនុស្សឥឡូវវាមានម៉ូតូជិះអីចឹងទៅណា ម៉ូតូជិះចង់គ្រប់ផ្ទះ ពីដើមអត់មានទេ កង់ក៏មិនមានផង កាលជំនាន់ខ្ញុំនោះ ឥឡូវវាមានម៉ូតូ ។

ដានីៈ ចុះអឹដូចថា បងប្អូនអឹបង្កើត ឪពុកអឹអី ដូចថាអឹបែកយូ ដល់ពេលឃើញអឹលើកទី១ គាត់មើលអឹស្គាល់ទេ អឹមើលបងប្អូនស្គាល់ដែរអត់?

ចៀមៈ ស្គាល់! កាលហ្នុងចុះកាសែត បងខ្ញុំមើលកាសែតបានដឹងថាខ្ញុំនៅនេះ បានគាត់ចាក់មកតាមកាកបាទក្រហម ខ្ញុំដឹងថាសុខទុក្ខខាងនោះវាមានអីចឹង កាលហ្នុងម៉ែឪខ្ញុំនៅទាំងអស់ កាលហ្នុងក្រោយថ្ងៃ៥ ថ្ងៃ៦ ឆ្នាំ៩៧ ចប់រឿងហ្នុង ខ្ញុំសុំទៅ ។

ដានីៈ ពេលឃើញបងប្អូនលើកទី១ ឃើញឪពុកម្តាយ មានអារម្មណ៍យ៉ាងម៉េចទៅ?

ចៀមៈ សប្បាយរីករាយ អរណាស់ ។

ដានីៈ ចុះអឹ! កាលជំនាន់ពាឆ្នាំ ដូចថាអឹមានតួនាទី មានតំណែងអីក្អួរសមដែរ ម៉េចបានអឹអត់បានទៅលេងផ្ទះអឹ ឬអឹអត់ចង់ទៅលេង?

ចៀមៈ នែ! គម្រោងខ្ញុំគិតថាទៅលេងឆ្នាំ៧៩ កាលនោះវារវល់មែនទែន រវល់នៅក្រសួង រវល់ទទួលភ្ញៀវ រៀបចំផ្ទះសម្បែងទទួលភ្ញៀវ រវល់នោះរវល់ពេកម៉ង ខ្ញុំពាឆ្នាំ ខ្ញុំបានទៅចិនម្តងដែរ ។

ដានីៈ ទៅចិនម្តងដែរ!

ចៀមៈ បាទ ។

ដានីៈ ទៅឆ្នាំណា? .

ចៀមៈ ឆ្នាំ៧៦ ។

ដានីៈ ទៅធ្វើអី ទៅទស្សនៈកិច្ច ឬទៅរៀន?

ចៀមៈ ទៅជាមួយតាប៉ុល ពត ហ្នឹងណា....វ៉ន វេត តាឌឿន ...៥នាក់ដឹកនាំទៅ ។

ដានីៈ ទៅទស្សនៈបានប៉ុន្មានថ្ងៃ?

ចៀមៈ មួយខែជាង ។

ដានីៈ ទៅមើលបានកន្លែងណាខ្លះណាហ្នុង?

ចៀមៈ ទៅប៉ុន្មានខេត្តណុះ កំណើត ក្វាង ស៊ី ផង អី យន់ណាន, នៅសៀងហៃ, ចាំមិនអស់ទេ មូលដ្ឋានតស៊ូរបស់ប្រធានម៉ៅនោះ...ទៅ៤,៥ខេត្តដែរ ។

ដានីៈ ទៅប៉េកាំងដែរ?

ចៀមៈ ប៉េកាំងទៅ មហាកំផែងទៅ ។

ដានីៈ អ៊ឹមានថតរូបថតអីទេ?

ចៀមៈ ថត! ប៉ុនអត់បានទេ ថតនៅចោលទាំងអស់ រូបថតកាលហ្នឹងថតនៅកន្លែងអង្គការទេទុកដាក់ យើងអត់មានសិទ្ធិអីយកទុកដាក់រឿងផ្ទាល់ខ្លួនទេអីអត់មានទេ កន្លែងរួមម៉ង ។

ដានីៈ កាលហ្នឹងបងប្អូនអ៊ឹគាត់អត់បានមកធ្វើការអីនៅភ្នំពេញ នៅតាមមូលដ្ឋានអី គាត់បានធ្វើការអីដែរអត់?

ចៀមៈ អត់ទេ! ប្អូនខ្ញុំគាត់ធ្វើពេទ្យ តាំងពី៣ឆ្នាំមកទល់ឥឡូវគាត់ធ្វើពេទ្យ បងទី១នៅផ្ទះ ។

ដានីៈ កាលជំនាន់៣ឆ្នាំក៏គាត់អត់ធ្វើអីដែរ?

ចៀមៈ អត់ទេ!

ដានីៈ កាលហ្នឹងអ៊ឹក៏អត់មាននាំបងប្អូនអីមកនៅភ្នំពេញអីក៏អត់ដែរ?

ចៀមៈ អត់ទេ!

ដានីៈ ចុះបងប្អូនអ៊ឹ ពួកគាត់ធ្លាប់មកលេងនៅម៉ាខ្មែរនេះទេ?

ចៀមៈ អត់ទេ! បានតែប្អូនស្រីមួយ ប៉ុនវាស្លាប់បានទៅហើយ ពុកខ្ញុំគាត់មកដល់នេះ មកដល់នេះ ៤ខែ សុំត្រឡប់ទៅវិញក៏ទៅវិញទៅ គាត់ត្រឡប់ទៅវិញកាល២០០៦ ។

ដានីៈ គាត់មកនៅនេះបាន៤ខែដែរ?

ចៀមៈ បាន៤ខែ នេះរូបថត ពុកខ្ញុំ ម៉ែខ្ញុំ ។

ដានីៈ ម្ដាយអ៊ឹគាត់ខូចនៅអាយុប៉ុន្មានទៅ?

ចៀមៈ ៧៨ ។

ដានីៈ ពុក អ៊ឹមកដល់ឥឡូវ៩២ហើយ អាយុវែងណាស់ ។ ចុះអ៊ឹពេលដែលទៅដល់ស្រុកអីចឹង ចុះញាតិមិត្ត ដូចថាមិត្តភក្តិ អ្នកស្រុកដែលធ្លាប់ស្គាល់គ្នាកាលពីក្មេងៗម៉េចទៅប្លែក គេស្គាល់អ៊ឹទេ?

ចៀមៈ ប្លែក! ជួបគ្នាសប្បាយរីករាយណាស់... ស្លាប់ក៏អស់ច្រើនដែរ ។

ដានីៈ ដូចថាអ៊ឹនៅណោះ ដូចថាលែងចង់ទៅនៅស្រុកវិញអត់ទេ?

ចៀមៈ អត់មានលទ្ធភាព យើងតាំងភូមិគ្រឹះនៅនេះហើយ នៅនេះទៅ វាអត់មានទន់ បើមានទុនចង់ដែរ មើលទៅ មើលសភាពការជាក់ស្តែងទៅមិនរួច ។

ដានីៈ ម៉េចបានអ៊ីចង់ទៅនៅស្រុកវិញ?

ចៀមៈ ចង់ដែរ ដូចថាបងប្អូននៅនោះច្រើន នៅនេះតែម្នាក់ឯង បងប្អូននៅនោះនៅសល់៣នាក់នៅខេត្តខ្ញុំឯងចង់ដែរ ។

ដានីៈ ចុះអ៊ីដូចថាយើងឆ្ងាយយូរនៅតែឯងអីចឹង អ៊ីខាននិយាយភាសាជនជាតិអ៊ីយូ ដល់ពេលអ៊ីទៅវិញអ៊ីនៅនិយាយអីច្បាស់ដូចថានៅចាំអីចឹងដែរឬយ៉ាងម៉េច?

ចៀមៈ ដំបូងតាំង១ដែរ ប៉ុនទៅនៅមួយអាទិត្យទៅអត់អីទេ ធម្មតាវិញ ។

ដានីៈ នៅក្នុងគ្រួសារអ៊ីនេះ អ៊ីនិយាយភាសាជនជាតិ ឬក៏និយាយខ្មែរ?

ចៀមៈ និយាយខ្មែរ ។

ដានីៈ បាទ! អីចឹងអ៊ីខ្ញុំអរគុណច្រើនដែលចំណាយពេលជួបខ្ញុំនេះយូដែរ ។

ចៀមៈ បាទ!

«ចប់»